ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសកម្មភាពសម្រាប់
# អនុវត្តគោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ
# ដើម្បីបង្កើនភាពស៊ាំប្រឆាំងនឹងមេរោគកូវីដ-១៩

រៀបចំដោយ

**គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស**

ខែកញ្ញា ឆ្នាំ២០២១

# អារម្ភកថា

ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រឆ្លើយតបបន្ទាន់ជាបន្តបន្ទាប់ ដើម្បីការពារអាយុជីវិតប្រជាពលរដ្ឋកម្ពុជា ការពារប្រព័ន្ធសុខាភិបាល និងកាត់បន្ថយផលប៉ះពាល់លើជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងលើសកម្មភាពសង្គម-សេដ្ឋកិច្ច។ ក្នុងនោះយុទ្ធសាស្ត្រចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ត្រូវបានរាជរដ្ឋាភិបាលចាត់ទុកថាជាយុទ្ធសាស្ត្រគន្លឹះមួយ ក្នុងការបង្ការ កាត់បន្ថយ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩ ដើម្បីបង្កើតឱ្យបាននូវភាពស៊ាំក្នុងសហគមន៍ សំដៅឈានឆ្ពោះទៅបើកដំណើរការពេញលេញឡើងវិញលើគ្រប់វិស័យ និងការរស់នៅតាមគន្លងប្រក្រតីភាពថ្មី។

បច្ចុប្បន្នដោយមានការរាតត្បាតនៃមេរោគកូវីដ-១៩ បំប្លែងខ្លួនប្រភេទដែលតា ក្នុងសហគមន៍ បាននាំមកនូវបញ្ហាប្រឈមថ្មីមួយទៀតដល់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដោយសារការចម្លងរបស់មេរោគនេះមានល្បឿនលឿន បង្កភាពធ្ងន់ធ្ងរដល់អ្នកជំងឺ អាចបណ្តាលឱ្យអត្រាស្លាប់ខ្ពស់ជាងប្រភេទមេរោគកូវីដ-១៩ ផ្សេងៗទៀត និងបន្ថយប្រសិទ្ធភាពនៃវ៉ាក់សាំង។ អ្នកវិទ្យាសាស្ត្រជាច្រើនបានធ្វើការស្រាវជ្រាវ និងបានបង្ហាញទន្និករណ៍បែបវិទ្យាសាស្ត្រអំពីប្រសិទ្ធភាពនៃវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញ ដែលបង្កើនភាពឆ្លើយតបនៃអង្គបដិបក្ខក្នុងខ្លួនឱ្យកាន់តែប្រសើរឡើងថែមទៀត ដើម្បីប្រឆាំងនឹងមេរោគកូវីដ-១៩ បំប្លែងខ្លួនប្រភេទថ្មីៗ ជាពិសេស មេរោគកូវីដ-១៩ បំប្លែងខ្លួនប្រភេទដែលតា ហើយប្រទេសមួយចំនួនបានដាក់ចេញនូវយុទ្ធនាការចាក់វ៉ាក់សាំងដូសជំរុញ។ នៅក្នុងបរិការណ៍នេះ នៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២១ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ដែលត្រូវចាប់ផ្តើមនៅក្នុងខែសីហា ឆ្នាំ២០២១ រហូតដល់អំឡុងពាក់កណ្តាលឆ្នាំ២០២២ ដើម្បីពង្រឹងប្រព័ន្ធការពារឱ្យបានរឹងមាំបន្ថែមទៀត។

រាជរដ្ឋាភិបាលខិតខំប្រឹងប្រែងគ្រប់មធ្យោបាយ ដើម្បីរកវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ចាក់ជូនដល់ប្រជាពលរដ្ឋកម្ពុជា ដោយមិនបង់ថ្លៃសម្រាប់ដូសទី១ និងដូសទី២ និងនៅតែបន្តសម្រាប់វ៉ាក់សាំងដូសជំរុញ។ ទន្ទឹមនេះ ដើម្បីបង្កើនល្បឿននៃការចាក់វ៉ាក់សាំងដូសជំរុញនេះ ក៏ដូចជាដើម្បីកាត់បន្ថយបន្ទុកចំណាយថវិកាជាតិ រាជរដ្ឋាភិបាលលើកទឹកចិត្ត និងអំពាវនាវដល់ប្រជាជនដែលមានលទ្ធភាពគ្រប់គ្រាន់ ឱ្យទៅទទួលការចាក់វ៉ាក់សាំងដូសជំរុញនេះ នៅតាមគ្រឹះស្ថាន សុខាភិបាលឯកជន ដែលទទួលបានការអនុញ្ញាតឱ្យផ្តល់សេវាចាក់វ៉ាក់សាំងកូវីដ-១៩ នេះ។ ដោយឡែក បណ្តារោងចក្រ សហគ្រាស និងម្ចាស់អាជីវកម្មទាំងអស់ ក៏ត្រូវបានលើកទឹកចិត្តឱ្យចូលរួមចំណែកចែករំលែកបន្ទុកចំណាយជាមួយរាជរដ្ឋាភិបាល ក្នុងការផ្តល់ការចាក់ វ៉ាក់សាំងដូសជំរុញនេះដល់បុគ្គលិក និងកម្មករ-និយោជិតរបស់ខ្លួនឱ្យបានគ្រប់គ្នា ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ នៅតាមរោងចក្រ-សហគ្រាស និងទីតាំងអាជីវកម្ម និងធានាបាននូវសុវត្ថិភាព និងនិរន្តរភាពនៃកិច្ចដំណើរការផលិតកម្មជាប្រក្រតីនៅក្នុងរោងចក្រ-សហគ្រាស ឬអាជីវកម្មរបស់ខ្លួន។

ការដាក់ចេញឱ្យអនុវត្តនូវ **ផែនការសកម្មភាពសម្រាប់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ដូសជំរុញដើម្បីបង្កើនភាពស៊ាំទប់ទល់នឹងមេរោគកូវីដ-១៩** រៀបចំឡើងស្របតាមខ្លឹមសារនៃគោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញរបស់រាជរដ្ឋាភិបាល។ ផែនការនេះមានគោលបំណង កាត់បន្ថយការឆ្លង ភាពធ្ងន់ធ្ងរនៃជំងឺ ការឈឺ សម្រាកពេទ្យ និងស្លាប់ដែលបណ្តាលមកពីជំងឺកូវីដ-១៩ និងទប់ទល់នឹងការគម្រាមកំហែងនៃមេរោគបំប្លែងខ្លួនប្រភេទថ្មីៗ តាមរយៈការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញដល់ប្រជាពលរដ្ឋដែលមានអាយុចាប់ពី១២ឆ្នាំឡើង។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ អនុគណៈកម្មការផែនការ និងថវិកានីយកម្ម អនុគណៈកម្មការនានា និងសូមថ្លែងអំណរគុណចំពោះអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្តចំណុះគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) ព្រមទាំងការសហការពីអជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ និងបុគ្គលិកសុខាភិបាលទាំងអស់ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនប្រជាពលរដ្ឋកម្ពុជាកន្លងមក និងដែលបានផ្តល់ធាតុចូលក្នុងការកសាងផែនការដ៏មានសារសំខាន់នេះ។

ខ្ញុំសង្ឃឹមថា **ផែនការសកម្មភាពសម្រាប់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសជំរុញដើម្បីបង្កើនភាពស៊ាំទប់ទល់នឹងមេរោគកូវីដ-១៩** នឹងត្រូវបានយកទៅអនុវត្តប្រកប ដោយស្មារតីទទួលខុសត្រូវ និងទទួលបានប្រសិទ្ធភាពខ្ពស់ ដើម្បីជាគុណប្រយោជន៍ដ៏ធំធេងសម្រាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។

ថ្ងៃចន្ទ ៦រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**

**ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩)**

វេជ្ជ. ឱ្យ វណ្ណឌីន

# មាតិកា


អារម្ភកថា ..... i

មាតិកា ..... iii

1 សេចក្តីផ្តើម ..... 1

1.1 សារបាន ..... 1

1.2 សន្និធានកម្ម ..... 1

1.3 បញ្ហាប្រឈម និងភាពលានុវត្តភាព ..... 3

2 គោលបំណង និងគោលដៅ ..... 4

2.1 គោលបំណង ..... 4

2.2 គោលដៅ ..... 4

2.3 គោលការណ៍នៃចាក់វ៉ាក់សាំងជូសជំរុញ ..... 5

3 អតិក្រមនៃការចាក់វ៉ាក់សាំងជូសជំរុញ ..... 6

3.1 លក្ខណៈវិនិច្ឆ័យសម្រាប់ការចាក់វ៉ាក់សាំងជូសជំរុញ ..... 6

3.2 របបចាក់វ៉ាក់សាំងជូសជំរុញ ..... 7

3.3 នីតិវិធីដើម្បីទទួលបានការចាក់វ៉ាក់សាំងជូសជំរុញ ..... 8

3.4 ការកំណត់ និងការរៀបចំទីតាំងចាក់វ៉ាក់សាំង ..... 9

3.5 កិច្ចសហការរវាងរដ្ឋ និងវិស័យឯកជនក្នុងការចាក់វ៉ាក់សាំងជូសជំរុញ ..... 10

3.6 ក្រុមការងារចាក់វ៉ាក់សាំង ..... 11

3.7 ការដឹកនាំ និងគ្រប់គ្រងការងារចាក់វ៉ាក់សាំងកូវីដ-១៩ ..... 11

3.8 ការគ្រប់គ្រងវ៉ាក់សាំង និងសំណល់ក្រោយការចាក់វ៉ាក់សាំង ..... 12

3.9 ការអប់រំផ្សព្វផ្សាយនិងតាមដានផលរំខានក្រោយការចាក់វ៉ាក់សាំង ..... 13

3.10 ការពិនិត្យតាមដាន វាយតម្លៃ និងការបិទបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំង ..... 13

4 ការអនុវត្តផែនការចាក់វ៉ាក់សាំងកូវីដ-១៩ ជូសជំរុញ ..... 16

4.1 ជំហាននៃការចាក់វ៉ាក់សាំងជូសជំរុញ ..... 16

4.2 តម្រូវការវ៉ាក់សាំង ..... 19

# 1 សេចក្តីផ្តើម

## 1.1 សារបាន

រាជរដ្ឋាភិបាលកម្ពុជាបានបើកយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ជុំទី១ ដល់ប្រជាពលរដ្ឋអាយុពី១៨ ឆ្នាំឡើង នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ និងជុំទី២ ដល់កុមារ-យុវវ័យអាយុពី ១២ឆ្នាំ ដល់ក្រោម១៨ឆ្នាំ នៅថ្ងៃទី ០១ ខែសីហា ឆ្នាំ២០២១។ គិតត្រឹមថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០២១ ៥៨,៣៩% នៃប្រជាជនកម្ពុជាសរុប ១៦.៥៩២.០៨៩នាក់ បានចាក់វ៉ាក់សាំងកូវីដ-១៩ ២ដូស។ ក្រោយបញ្ចប់យុទ្ធនាការនេះ ប្រទេសកម្ពុជានឹងសម្រេចបានអត្រាគ្របដណ្តប់នៃការចាក់វ៉ាក់សាំងកូវីដ-១៩ ២ដូសប្រមាណ ៧៧% នៃប្រជាជនកម្ពុជាសរុប។ នៅថ្ងៃទី២៥ ខែសីហាឆ្នាំ២០២១ **សម្តេចអគ្គមហា-សេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនូវ «គោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ» សំដៅបង្កើតឱ្យបាននូវភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយ សម្រាប់ព្រះរាជាណាចក្រកម្ពុជា តាមរយៈសេចក្តីប្រកាស លេខ ០១ ស.ប្រ.ក ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០២១ ។

## 1.2 សន្និទានកម្ម

ការសិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រជាច្រើនបង្ហាញថា វ៉ាក់សាំងជួយកាត់បន្ថយការឆ្លងការឈឺសម្រាកពេទ្យ និងការស្លាប់ដែលបណ្តាលមកពីជំងឺកូវីដ-១៩ ក្រោយពេលចាក់ពេញលេញតាមរបបកំណត់ និងបញ្ជាក់ដែរថា មេរោគបំប្លែងខ្លួនប្រភេទថ្មីៗ ដូចជាមេរោគប្រភេទដែលតា ជាដើម មានសមត្ថភាពបន្ថយប្រសិទ្ធភាពវ៉ាក់សាំង។ ក្នុងបរិបទនេះប្រទេសជាច្រើនបានរៀបចំផែនការ និងប្រទេសមួយចំនួនទៀតកំពុងដំណើរការចាក់វ៉ាក់សាំងដូសជំរុញ ដល់ប្រជាពលរដ្ឋរបស់ខ្លួន ដោយប្រើប្រាស់ «របបចាក់វ៉ាក់សាំងចម្រុះនិងចុះសម្រុងគ្នា» រវាងប្រភេទវ៉ាក់សាំងផ្សេងគ្នានៃដូសទី១, ទី២ និងដូសជំរុញ (តារាង ១.១) ពីព្រោះរបបចាក់វ៉ាក់សាំងបែបនេះជួយបង្កើនភាពឆ្លើយតបនៃអង្គបដិប្រាណខ្ពស់ជាងការចាក់វ៉ាក់សាំងប្រភេទដូចគ្នា ។ រីឯការសិក្សាស្រាវជ្រាវផ្សេងទៀតបញ្ជាក់ថា «របបចាក់វ៉ាក់សាំងប្រភេទដូចគ្នា» ដោយប្រើប្រាស់វ៉ាក់សាំងប្រភេទតែមួយ សម្រាប់ ដូសទី១, ទី២ និងដូសជំរុញ ក៏ជួយបង្កើនអង្គបដិប្រាណ កើនឡើងខ្ពស់ទប់ទល់នឹងមេរោគកូវីដ-១៩ ដោយរាប់បញ្ចូលទាំងមេរោគបំប្លែងខ្លួន ហើយដូសទី៣ ឬដូសជំរុញនេះ ក៏មិនបង្កឱ្យមានផលរំខានច្រើនដែរ ដូចជាការចាក់ដូសទី៣ នៃវ៉ាក់សាំង AstraZeneca ៦ ខែក្រោយការចាក់ដូសទី២[1] ឬការចាក់វ៉ាក់សាំង Sinovac ៦ ខែក្រោយការចាក់ដូសទី២[2] ជាដើម។

---

[1] Third shot of Oxford/AstraZeneca vaccine 'could be effective booster' 28 June 2021 https://www.itv.com/news/2021-06-28/third-shot-of-oxfordastrazeneca-vaccine-could-be-effective-booster)

[2] Sinovac booster shot reverses drop-in antibody activities against Delta-study https://www.reuters.com/business/healthcare-pharmaceuticals/sinovac-booster-shot-reverses-drop-antibody-activities-against-delta-study-2021-09-06

ក្រៅពីទឡ្ហីករណ៍ខាងលើនេះ ក្រុមសិក្សាស្រាវជ្រាវឯកសារនៃក្រសួងសុខាភិបាលកម្ពុជា ក៏បានរកឃើញ និងធ្វើការសន្និដ្ឋានថា៖ (១) កម្រិតភាពស៊ាំប្រឆាំងនឹងមេរោគគូវីដ-១៩ អាចស្ថិតនៅរយៈពេលប្រមាណពី ៦ ទៅ ៨ ខែ ជាទូទៅ ក្រោយពេលចាក់វ៉ាក់សាំងមូលដ្ឋានគ្រប់ដូសរួច (២)គម្លាតពេលវេលាសមស្របសម្រាប់ការចាក់ដូសជំរុញ គប្បីមានរយៈពេលប្រមាណពី ៦-៨ ខែ ក្រោយពេលចាក់វ៉ាក់សាំងគ្រប់ដូស និង(៣) «របបចាក់វ៉ាក់សាំងចម្រុះនិងចុះសម្រុងគ្នា» ឬ «របបចាក់វ៉ាក់សាំងប្រភេទដូចគ្នា» បង្កើនអង្គបដិប្រាណកម្រិតខ្ពស់ ហើយក៏មិនបង្កឱ្យមានផលរំខានច្រើនលើសពីផលរំខាន ដែលបង្កឡើងដោយប្រភេទវ៉ាក់សាំងនីមួយៗ ដែរ។

## តារាង ១.១ ប្រទេសបានចាប់ផ្តើម/បានរៀបចំផែនការចាក់វ៉ាក់សាំងដូសជំរុញ [3]

| ប្រទេស | ពេលវេលា | ក្រុមប្រជាជន | ប្រភេទវ៉ាក់សាំងដូសជំរុញ |
|---|---|---|---|
| **អារ៉ាប់អេមីរ៉ាត** | ខែមិថុនា២០២១ | ប្រជាជនទូទៅបានចាក់វ៉ាក់សាំងពេញលេញ៖ ៣ខែក្រោយ ចំពោះអ្នកមានហានិភ័យខ្ពស់និង ៦ខែក្រោយចំពោះប្រជាជនដទៃទៀត | Pfizer សម្រាប់អ្នកបានចាក់ Sinopharm ពីពេលមុន |
| **រុស្ស៊ី** | ខែកក្កដា២០២១ | ប្រជាជនដែលបានវ៉ាក់សាំងពី ៦ ខែមុន | |
| **ហុងគ្រី** | ខែកក្កដា២០២១ | ក្រុមគ្រូពេទ្យ យ៉ាងតិច ៤ ខែក្រោយការចាក់ពេញលេញ(ជាទូទៅប្រើប្រាស់វ៉ាក់សាំងមូលដ្ឋានផលិតនៅប្រទេសរុស្ស៊ី និងប្រទេសចិន) | Pfizer, Moderna and AstraZeneca |
| **ឥណ្ឌូនេស៊ី** | ខែកក្កដា២០២១ | ក្រុមគ្រូពេទ្យ (ជាទូទៅប្រើប្រាស់វ៉ាក់សាំង AstraZeneca, Sinovac និង Sinopharm) | Moderna |
| **អ៊ីស្រាអែល** | ខែកក្កដា២០២១ | មនុស្សអាយុពី៦០ឆ្នាំឡើង និង៥ខែក្រោយបានចាក់វ៉ាក់សាំងពេញលេញ | Pfizer/BioNTech |
| **បារាំង** | ខែកញ្ញា ២០២១ | មនុស្សចាស់ៗ និងក្រុមប្រជាជនងាយរងគ្រោះ | |
| **អង់គ្លេស** | ខែកញ្ញា ២០២១ | មនុស្សចាស់ៗ និងក្រុមប្រជាជនងាយរងគ្រោះ | Pfizer/BioNTech |
| **អាល្លឺម៉ង់** | ខែកញ្ញា ២០២១ | ក្រុមប្រជាជនងាយរងគ្រោះ (មនុស្សចាស់, អ្នកមានប្រព័ន្ធការពារខ្លួនខ្សោយ) | mRNA-vaccines (Pfizer/BioNTech and Moderna) មិនគិតពីប្រភេទវ៉ាក់សាំងចាក់ពីពេលមុន |
| **ស៊ុយអែត** | ខែកញ្ញា ២០២១ | ក្រុមប្រជាជនមានហានិភ័យខ្ពស់ រឺឯប្រជាជនភាគច្រើននៅឆ្នាំ២០២២ | |
| **ថៃ** | | ក្រុមប្រជាជនជួរមុខ | mRNA-vaccines សម្រាប់អ្នកបានចាក់ Sinovac ពីពេលមុន |
| **សឹង្ហបុរី** | ចុងឆ្នាំ២០២១ ឬ ដើមឆ្នាំ២០២២ | | |
| **កូរ៉េខាងត្បូង** | ឆ្នាំ២០២២ | | mRNA vaccines |

[3] Fact box: Countries weigh need for booster COVID-19 shots. https://www.reuters.com/business/healthcare-pharmaceuticals/countries-weigh-need-booster-covid-19-shots-2021-08-05/

## 1.3 បញ្ហាប្រឈម និងកាលានុវត្តភាព

### ក. បញ្ហាប្រឈម

- កម្ពុជាប្រើប្រាស់ជាទូទៅវ៉ាក់សាំង Sinopharm និង Sinovac សម្រាប់ដូសទី១ និងទី២ ដូច្នេះការជ្រើសរើសយកវ៉ាក់សាំងប្រភេទ Viral vector ឬ mRNA សម្រាប់ដូសជំរុញ អាចប្រឈមនឹងកង្វះវ៉ាក់សាំង ដោយសារទីផ្សារផ្គត់ផ្គង់វ៉ាក់សាំងមិនទាន់អាចឆ្លើយតបបាននឹងតម្រូវការដ៏ខ្ពស់ក្នុងក្របខណ្ឌសកលលោក។ ជាក់ស្តែង គិតត្រឹមខែកក្កដា ឆ្នាំ២០២១ ត្រឹមតែ ១% នៃប្រជាជនក្នុងប្រទេសមានប្រាក់ចំណូលទាបបានចាក់វ៉ាក់សាំងកូវីដ-១៩ មួយដូស, ១៤% ក្នុងប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប, ៣១% ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និង ៥១% ក្នុងប្រទេសមានប្រាក់ចំណូលខ្ពស់[4] ។
- បន្ទុកការងារនៅមូលដ្ឋានសុខាភិបាលអាចកើនឡើង ហើយអាចត្រូវការធនធានបន្ថែម ជាពិសេសធនធានមនុស្ស ដោយសារការចាក់វ៉ាក់សាំងដូសជំរុញចាប់ផ្តើម នៅខណៈពេលដែលការចាក់វ៉ាក់សាំងជុំទី១ និងជុំទី២ កំពុងដំណើរការ ប៉ុន្តែស្ថានភាពនេះនឹងធូរស្រាវិញ នៅពេលការចាក់វ៉ាក់សាំងជុំទី១ និងជុំទី២ ត្រូវបានបិទបញ្ចប់យ៉ាងយូរនៅក្នុងខែវិច្ឆិកាខាងមុខនេះ។

### ខ. កាលានុវត្តភាព

- កិច្ចដំណើរការចាក់វ៉ាក់សាំងជុំទី១ និងជុំទី២ ផ្តល់នូវបទពិសោធន៍ជាក់ស្តែងគ្រប់គ្រាន់ សម្រាប់ការត្រៀមលក្ខណៈឱ្យបានរួចរាល់ទុកជាមុនផង និងដំណើរការចាក់វ៉ាក់សាំងដូសជំរុញផង។
- ប្រព័ន្ធ យន្តការ និងសេវាគាំទ្រចាំបាច់នានា ដែលកំពុងដំណើរសម្រាប់ការចាក់វ៉ាក់សាំងជុំទី១ និងជុំទី២ និងធនធានមនុស្សដែលមានចំណេះដឹងនិងបទពិសោធន៍ក្នុងការងារចាក់វ៉ាក់សាំង ផ្តល់នូវមូលដ្ឋានរឹងមាំផ្នែកបច្ចេកទេស និងភស្តុភារដល់ដំណើរការចាក់វ៉ាក់សាំងដូសជំរុញ។
- ស្ថានភាពនៃការឆ្លងរាតត្បាតបច្ចុប្បន្នស្ថិតនៅក្រោមការគ្រប់គ្រង ទោះបីជាមេរោគបំប្លែងខ្លួនប្រភេទដែលតា ត្រូវបានរកឃើញជាបន្តបន្ទាប់នៅក្នុងសហគមន៍ក្តី។
- រាជរដ្ឋាភិបាលបានត្រៀមបម្រុងរួចជាស្រេច នូវបរិមាណវ៉ាក់សាំងសម្រាប់ក្រុមប្រជាពលរដ្ឋជាគោលដៅអាទិភាព ដែលត្រូវការចាក់ដូសជំរុញ។
- ការអនុញ្ញាតិឱ្យវិស័យឯកជននាំចូល និងចែកចាយវ៉ាក់សាំងកូវីដ-១៩ និងផ្តល់សេវាចាក់វ៉ាក់សាំងអាចជួយពន្លឿនការគ្របដណ្តប់នៃការចាក់វ៉ាក់សាំងដូសជំរុញបានលឿន និងជួយកាត់បន្ថយបន្ទុកការងារចាក់វ៉ាក់សាំងមួយផ្នែកនៃប្រព័ន្ធសុខាភិបាល។

---

[4] https://www.kff. org/ coronavirus-covid-19/issue-brief/tracking-global-covid-19-vaccine-equity

# 2 គោលបំណង និងគោលដៅ

## 2.1 គោលបំណង

“ការពារអាយុជីវិតប្រជាពលរដ្ឋកម្ពុជា ការពារប្រព័ន្ធសុខាភិបាល និងកាត់បន្ថយផលប៉ះពាល់សង្គម-សេដ្ឋកិច្ចដែលបណ្តាលមកពីជំងឺកូវីដ-១៩តាមរយៈការអនុវត្តសេចក្តីប្រកាសគោលនយោបាយស្តីពីការចាក់វ៉ាក់សាំងដូសជំរុញរបស់រដ្ឋាភិបាល”

## 2.2 គោលដៅ

“កាត់បន្ថយការឆ្លង ភាពធ្ងន់ធ្ងរនៃជំងឺ អ្នកជំងឺសម្រាកពេទ្យ និងស្លាប់ដែលបណ្តាលមកពីជំងឺកូវីដ-១៩ និងទប់ទល់នឹងការគម្រាមកំហែងនៃមេរោគបំប្លែងខ្លួនប្រភេទថ្មីៗ តាមរយៈការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ដល់ប្រជាពលរដ្ឋអាយុពី ១២ឆ្នាំឡើង ឱ្យបានយ៉ាងតិច ៩០% នៅដំណាច់ខែមិថុនា ឆ្នាំ២០២២”

ការសម្រេចគោលដៅកំណត់ខាងលើ នឹងត្រូវបានវាស់វែងដោយសូចនាករខាងក្រោម៖

- យ៉ាងតិច ៩០% នៃប្រជាពលរដ្ឋអាយុពី១៨ ឆ្នាំឡើង បានចាក់ដូសជំរុញ (ចំនួន ១០.៧៩៦.៤៥០នាក់) បន្ទាប់ពីបានចាក់វ៉ាក់សាំងចាក់ដូសទី២ រួច
- យ៉ាងតិច ៩០% នៃប្រជាពលរដ្ឋអាយុពី១២ឆ្នាំ ទៅក្រោម១៨ឆ្នាំ បានចាក់ដូសជំរុញ (ចំនួន ១.៩៦៦.៩៣១នាក់) បន្ទាប់ពីបានចាក់វ៉ាក់សាំងចាក់ដូសទី២ រួច

ប្រជាជនគោលដៅសរុបសម្រាប់ការវ៉ាក់សាំងដូសជំរុញ មានប្រមាណ ១២.៧៦៣.៣៨១នាក់ តាមការប៉ាន់ប្រមាណ ដោយផ្អែកលើសម្មតិកម្មខាងក្រោមនេះ៖

- នៅឆ្នាំ២០២១ ប្រជាជនកម្ពុជាមានចំនួនសរុប ១៦.៥៩២.០៨៩នាក់ ក្នុងនោះប្រជាជនជាគោលដៅនៃការចាក់វ៉ាក់សាំងអាយុពី១៨ឆ្នាំឡើង មានចំនួន ១០.៩០០.០០០នាក់ និងអាយុពី១២ឆ្នាំ ទៅក្រោម១៨ឆ្នាំ មានចំនួន ១.៩៦៦.៩៣១នាក់ (ប៉ាន់ប្រមាណដោយផ្អែកលើទិន្នន័យជំរឿនទូទៅប្រជាជនកម្ពុជា ឆ្នាំ២០១៩)។
- ០,៩៥% នៃប្រជាពលរដ្ឋស្ម័គ្រចិត្តមកចាក់វ៉ាក់សាំងកូវីដ-១៩ ដែលមិនត្រូវបានគ្រូពេទ្យអនុញ្ញាតឱ្យចាក់ដោយសារបញ្ហាសុខភាពផ្ទាល់ខ្លួន។ អត្រានេះត្រូវបានកត់សម្គាល់ឃើញលើក្រុមប្រជាជនអាយុពី១៨ឆ្នាំឡើង ជាង ៧ លាននាក់ ដែលបានស្ម័គ្រចិត្តមកចាក់វ៉ាក់-សាំងដូសទី១។
- ១០០% នៃប្រជាជនជាគោលដៅអាយុពី ១២ឆ្នាំ ទៅក្រោម១៨ឆ្នាំ បានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី២ ។

## 2.3 គោលការណ៍នៃចាក់វ៉ាក់សាំងដូសជំរុញ

ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ត្រូវប្រព្រឹត្តតាមគោលការណ៍ណែនាំ ដែលបានចែងនៅក្នុង «សេចក្តីប្រកាសស្តីពីគោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ» លេខ ០១ សប្រក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល (ជូនភ្ជាប់ជាឧបសម្ព័ន្ធនៃឯកសារផែនការសកម្មភាពនេះ) រួមមានជាអាទិ៍៖

- **ស្ម័គ្រចិត្ត៖** រាជរដ្ឋាភិបាលបន្តអនុវត្តគោលការណ៍ស្ម័គចិត្ត សម្រាប់ការចាក់វ៉ាក់សាំងដូសជំរុញ និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋដែលមានលក្ខណៈសម្បត្តិ សមស្របតាមលក្ខខណ្ឌបច្ចេក-ទេសដែលបានចាក់វ៉ាក់សាំងជុំទី១ រួច មកទទួលយកវ៉ាក់សាំងដូសជំរុញ ឱ្យបានគ្រប់ៗគ្នា។
- **ឥតគិតថ្លៃ៖** ជារួម រាជរដ្ឋាភិបាលបន្តផ្តល់ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ជូនប្រជា-ពលរដ្ឋដោយឥតគិតថ្លៃ ដូចជុំទី១ ដែរ និងលើកទឹកចិត្តដល់ប្រជាជនដែលមានលទ្ធភាពឱ្យទៅទទួលការចាក់វ៉ាក់សាំងដូសជំរុញ នៅតាមសេវាសុខាភិបាលឯកជនដែលត្រូវបានអនុញ្ញាតឱ្យផ្តល់សេវាចាក់វ៉ាក់សាំងកូវីដ-១៩ និងលើកទឹកចិត្តដល់ម្ចាស់រោងចក្រ-សហគ្រាស និងអាជីវ-កម្មទាំងអស់ ឱ្យចូលរួមចែករំលែកបន្ទុកចំណាយជាមួយរាជរដ្ឋាភិបាល ក្នុងការផ្តល់ការចាក់វ៉ាក់សាំងដូសជំរុញ ដល់បុគ្គលិក និងកម្មករ-និយោជិតរបស់ខ្លួនឱ្យបានគ្រប់គ្នា។
- **ការធ្វើអាទិភាវូបនីយកម្ម៖** ការចាក់វ៉ាក់សាំងដូសជំរុញចាប់ផ្តើមចេញពីក្រុមមន្ត្រីសុខាភិបាល និងមន្ត្រីបម្រើការជួរមុខក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងចាប់ផ្តើមពីតំបន់មាន ហានិភ័យខ្ពស់ ប្រជាពលរដ្ឋមានអាយុចាប់ពី៦០ឆ្នាំឡើងទៅ និងប្រជាពលរដ្ឋដែលមានប្រព័ន្ធការពាររាងកាយខ្សោយ មុនពេលបន្តចាក់ជូនប្រជាពលរដ្ឋទូទៅ ស្របតាមអភិក្រម "ផ្ការីក" ដូចដែលបានអនុវត្តសម្រាប់យុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ នៅជុំទី១ ។
- **ការធានាប្រសិទ្ធភាព និងសុវត្ថិភាពនៃការចាក់វ៉ាក់សាំង៖** អនុញ្ញាតឱ្យប្រើប្រាស់តែប្រភេទវ៉ាក់-សាំងកូវីដ-១៩ ដែលត្រូវបានទទួលស្គាល់និងអនុញ្ញាតឱ្យប្រើប្រាស់ក្នុងគ្រាបន្ទាន់ដោយអង្គការសុខភាពពិភពលោកនិងដោយក្រសួងសុខាភិបាលកម្ពុជា និងកំណត់អំពីរបបនៃការចាក់វ៉ាក់សាំងដូសជំរុញ ទាំងរបបចាក់វ៉ាក់សាំងប្រភេទចម្រុះ ទាំងរបបចាក់វ៉ាក់សាំងប្រភេទតែមួយ។
- **យន្តការអនុវត្តគោលនយោបាយ៖** ក្រសួង-ស្ថាប័ន និងយន្តការដែលមានការពាក់ព័ន្ធត្រូវអនុវត្តគោលនយោបាយចាក់វ៉ាក់សាំងដូសជំរុញឱ្យមានប្រសិទ្ធភាពតាមភារៈកិច្ចរៀងៗ ខ្លួន រួមមានជាអាទិ៍៖ ការដឹកនាំសម្របសម្រួលការងាររួម និងតាមដានត្រួតពិនិត្យ, ការរៀបចំ និងអនុវត្តផែនការសកម្មភាពចាក់វ៉ាក់សាំងដូសជំរុញ, ការរៀបចំផែនការលទ្ធកម្ម និងស្វះស្វែងរកប្រភពផ្គត់ផ្គង់វ៉ាក់សាំង, ការរៀបចំយន្តការពិគ្រោះយោបល់ និងសម្របសម្រួលជាមួយយន្តការពាក់ព័ន្ធ និងរោងចក្រ-សហគ្រាស ម្ចាស់អាជីវកម្ម និងគ្រឹះស្ថានសុខាភិបាលឯកជន, ការគាំទ្រ និងសម្របសម្រួល ដើម្បីជួយឱ្យវិស័យឯកជនអាចនាំចូល និងផ្តល់សេវាចាក់វ៉ាក់សាំងដូសជំរុញ ឱ្យបានទូលំទូលាយជូនប្រជាពលរដ្ឋ ប្រកបដោយសុវត្ថិភាព និងក្នុងថ្លៃសមរម្យ។

# 3 អនុក្រមនៃការចាក់វ៉ាក់សាំងដូសជំរុញ

ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ នឹងប្រព្រឹត្តទៅព្រមពេលជាមួយគ្នានឹងការចាក់វ៉ាក់សាំងកូវីដ-១៩ ដល់ប្រជាពលរដ្ឋអាយុពី១២ ឆ្នាំឡើង តាមរយៈអនុក្រមដូចតទៅ៖

## 3.1 លក្ខណៈវិនិច្ឆ័យសម្រាប់ការចាក់វ៉ាក់សាំងដូសជំរុញ

**ក. គម្លាតពេលវេលារវាងការចាក់វ៉ាក់សាំងដូសទី២ និងដូសជំរុញ៖** ជារួម ការចាក់វ៉ាក់សាំងដូសជំរុញ ត្រូវធ្វើឡើង ៦ ខែក្រោយ បន្ទាប់ពីការចាក់ដូសទី២។ ដោយឡែក ដើម្បីឆ្លើយតបនឹងស្ថានការណ៍ចំពោះមុខនៃការចម្លងជំងឺកូវីដ-១៩ ក្នុងសហគមន៍ និងត្រៀមលក្ខណៈទប់ទល់នឹងការរាតត្បាតនៃមេរោគប្រភេទដែលតា និងប្រភេទបំប្លែងខ្លួនថ្មីផ្សេងទៀត ក្នុងទ្រង់ទ្រាយធំ គម្លាតពេលវេលានៃការចាក់វ៉ាក់សាំងដូសជំរុញ តាមប្រភេទវ៉ាក់សាំង ត្រូវបានកំណត់ជាបឋម ដូចបង្ហាញនៅក្នុងតារាង ៣.១។ ក្រសួងសុខាភិបាលនឹងបន្តសិក្សាស្រាវជ្រាវ និងធ្វើបច្ចុប្បន្នកម្មជាប្រចាំអំពីគម្លាតពេលវេលានេះ ហើយផ្សព្វផ្សាយព័ត៌មាន និងជូនដំណឹងដល់សេវាសុខាភិបាល និងសាធារណៈជន។

**តារាង ៣.១. ការកំណត់ជាបឋមនៃគម្លាតពេលវេលានៃការចាក់វ៉ាក់សាំងកូវីដ-១៩ ទៅតាមប្រភេទវ៉ាក់សាំង**

| ប្រភេទវ៉ាក់សាំង | ដូសទី១ | ដូសទី២ | ដូសជំរុញ |
|---|---|---|---|
| Sinopharm | ✓ | ✓២១-២៨ ថ្ងៃក្រោយចាក់ដូសទី១ | ✓ ៤-៦ ខែក្រោយចាក់ដូសទី២ |
| Sinovac | ✓ | ✓២១-២៨ ថ្ងៃក្រោយចាក់ដូសទី១ | ✓ ៤-៦ ខែក្រោយចាក់ដូសទី២ |
| AstraZeneca | ✓ | ✓ ១២ សប្តាហ៍ក្រោយ | ✓ ៤-៦ ខែក្រោយចាក់ដូសទី២ |
| Johnson & Johnson | ✓ | * | * |

*របបចាក់វ៉ាក់សាំងនេះត្រូវការតែមួយដូស។ ការចាក់ដូសជម្រុញនឹងត្រូវបានធ្វើបច្ចុប្បន្នកម្ម យោងតាមអនុសាសន៍របស់ក្រុមសិក្សាស្រាវជ្រាវឯកសារនៃក្រសួងសុខាភិបាល។

**ខ. កម្រិតហានិភ័យនៃការចម្លងជំងឺកូវីដ-១៩៖** ក្រុង-ស្រុក-ខណ្ឌដែលត្រូវបានវាយតម្លៃថា មានហានិភ័យខ្ពស់នៃការចម្លងជំងឺកូវីដ-១៩ និងបានរកឃើញមេរោគបំប្លែងខ្លួនប្រភេទដែលតា ត្រូវបានផ្តល់អាទិភាពខ្ពស់ សម្រាប់ការចាក់ដូសជំរុញ លើប្រជាពលរដ្ឋជាគោលដៅឱ្យបានឆាប់បំផុត តាមដែលអាចធ្វើបាន ដើម្បីឆ្លើយតបទៅនឹងស្ថានភាពចំពោះមុខនៃឆ្លងជំងឺកូវីដ-១៩ផង និងទប់ទល់នឹងមេរោគបំប្លែងខ្លួនប្រភេទដែលតាផង។ ក្នុងករណីដែលបរិមាណវ៉ាក់សាំងមានកម្រិត ក្រុមប្រជាពលរដ្ឋជាអាទិភាព ដូចបានកំណត់ក្នុងចំណុច **គ** ខាងក្រោមនេះ ត្រូវមានអាទិភាពចាក់វ៉ាក់សាំងដូសជំរុញមុនគេ។

**គ. ក្រុមប្រជាពលរដ្ឋជាអាទិភាព៖** ក្នុងពេលបច្ចុប្បន្ន ដែលការចម្លងក្នុងសហគមន៍នៅមានកម្រិតសកម្ម ហើយវត្តមាននៃមេរោគបំប្លែងខ្លួនប្រភេទដែលតា ត្រូវបានរកឃើញក្នុងសហគមន៍ ក្រុមគ្រូពេទ្យ

កងកម្លាំងអន្តរាគមន៍ កងទ័ពជួរមុខ និងប្រជាពលរដ្ឋអាយុចាប់ពីអាយុ៦០ឡើង/ប្រព័ន្ធការពារខ្លួនខ្សោយ ព្រមទាំងប្រជាពលរដ្ឋទាំងឡាយណាដែលកំពុងរស់នៅ ឬធ្វើការក្នុងតំបន់ភូមិសាស្ត្រ ឬនៅទីតាំងសកម្មភាពសង្គម-សេដ្ឋកិច្ចដែលមានហានិភ័យឆ្លងជំងឺកូវីដ-១៩ ខ្ពស់ ត្រូវទទួលបានការចាក់វ៉ាក់សាំងដូសជំរុញ យ៉ាងលឿនបំផុតតាមដែលអាចធ្វើទៅបានសំដៅបង្ការ និងគ្រប់គ្រងការឆ្លងរាតត្បាតក្នុងសហគមន៍ឱ្យបានរហ័ស។

## 3.2 របបចាក់វ៉ាក់សាំងដូសជំរុញ

ហូតមកដល់ពេលនេះ ប្រទេសកម្ពុជាប្រើប្រាស់វ៉ាក់សាំងកូវីដ-១៩ បួនប្រភេទ ដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងគ្រាបន្ទាន់ ដោយអង្គការសុខភាពពិភពលោក និងដោយក្រសួងសុខាភិបាលកម្ពុជា៖ វ៉ាក់សាំង Sinopharm, Sinovac (ផលិតនៅប្រទេសប្រទេសចិន), AstraZeneca (ផលិតនៅប្រទេសឥណ្ឌា ជប៉ុន និងអង់គ្លេស) និង Johnson & Johnson (ផលិតនៅសហរដ្ឋអាមេរិក)។ គួរគូសបញ្ជាក់ថា ប្រទេសកម្ពុជាប្រើប្រាស់វ៉ាក់សាំងប្រភេទតែមួយសម្រាប់ការចាក់ដូសទី១ និងដូសទី២ ហើយភាគច្រើនលើសលប់ គឺវ៉ាក់សាំង Sinopharm និង Sinovac។ ជារួម ការចាក់វ៉ាក់សាំងដូសជំរុញប្រើប្រាស់ «របបចាក់វ៉ាក់សាំងចម្រុះនិងចុះសម្រុងគ្នា» និង/ឬ «របបចាក់វ៉ាក់សាំងប្រភេទដូចគ្នា» ដូចបានកំណត់ជាបឋម ក្នុងតារាង ៣.២។ ក្រសួងសុខាភិបាលនឹងបន្តធ្វើបច្ចុប្បន្នកម្មជាប្រចាំអំពីរបបចាក់វ៉ាក់សាំងដូសជំរុញ ដោយយោងទៅតាមប្រភេទវ៉ាក់សាំងដែលអាចរកបានសម្រាប់ការចាក់ដូសជំរុញជូនប្រជាពលរដ្ឋ ហើយផ្សព្វផ្សាយព័ត៌មាន និងជូនដំណឹងដល់សេវាសុខាភិបាល និងសាធារណៈជន។ ដោយឡែក សម្រាប់ការចាប់ផ្តើមចាក់ដូសជំរុញ ដល់ក្រុមអាទិភាពដូចបានកំណត់ក្នុងគោលការណ៍អាទិភាវូបនីយកម្ម រាជរដ្ឋាភិបាលបានសម្រេចប្រើប្រាស់វ៉ាក់សាំងប្រភេទ AstraZeneca ជាវ៉ាក់សាំងដូសជំរុញ។

**តារាង ៣.២. ការកំណត់ជាបឋមអំពីរបបចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ និងប្រភេទវ៉ាក់សាំង**

| ប្រភេទវ៉ាក់សាំង | ដូសទី១ | ដូសទី ២ | ប្រភទវ៉ាក់សាំងដូសជំរុញ [5] |
|---|---|---|---|
| Sinopharm | ✓ | ✓ | វ៉ាក់សាំង Inactive virus ឬ Viral vector ឬ mRNA |
| Sinovac | ✓ | ✓ | វ៉ាក់សាំង Inactive virus ឬ Viral vector ឬ mRNA |
| AstraZeneca | ✓ | ✓ | វ៉ាក់សាំង Inactive virus ឬ Viral vector ឬ mRNA |
| Johnson & Johnson | ✓ | * | វ៉ាក់សាំង Inactive virus ឬ Viral vector ឬ mRNA |

*របបចាក់វ៉ាក់សាំងនេះនឹងត្រូវបានធ្វើបច្ចុប្បន្នកម្មយោងតាមអនុសាសន៍របស់ក្រុមសិក្សាស្រាវជ្រាវឯកសារនៃក្រសួងសុខាភិបាល។

[5] ក្រុមការងារជំនាញនៃក្រសួងសុខាភិបាលបានរកឃើញថាវ៉ាក់សាំង Sinopharm និង Sinovac អាចជាជម្រើសមានប្រសិទ្ធភាពសម្រាប់ជាដូសជំរុញ ទាំងចំពោះអ្នកដែលបានចាក់វ៉ាក់សាំងមូលដ្ឋានប្រភេទ Sinopharm ឬ Sinovac ទាំងចំពោះអ្នកដែលបានចាក់វ៉ាក់សាំងមូលដ្ឋានប្រភេទ AstraZeneca ឬ Johnson & Johnson

## 3.3 នីតិវិធីដើម្បីទទួលបានការចាក់វ៉ាក់សាំងដូសជំរុញ

**ក. ប្រជាពលរដ្ឋគោលដៅនៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ៖** ប្រជាពលរដ្ឋដែលមានលក្ខណៈសម្បត្តិសមស្របតាមលក្ខណៈវិនិច្ឆ័យដែលបានចែងក្នុងចំណុច ៣.១ អាចទៅចាក់វ៉ាក់សាំងដូសជំរុញនៅតាមទីតាំងចាក់វ៉ាក់សាំងនៃសេវាសុខាភិបាលសាធារណៈ តាមការជូនដំណឹងរបស់ គ.វ.ក-១៩ និងរបស់អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងរាជធានី-ខេត្ត និងក្រសួង-ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។ ចំណែកប្រជាពលរដ្ឋដែលមានលទ្ធភាពបង់ថ្លៃសេវា ក៏អាចទៅចាក់វ៉ាក់សាំងដូសជំរុញនៅសេវាសុខាភិបាលឯកជនផងដែរ។ នៅមុនពេលចាក់វ៉ាក់សាំងបុគ្គលម្នាក់ៗ៖

- ត្រូវបង្ហាញប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩ និងអត្តសញ្ញាណប័ណ្ណប្រជាជន (លើកលែងតែកុមារ-យុវវ័យ) ដល់គ្រូពេទ្យ/បុគ្គលិកដែលមានសមត្ថកិច្ចនៅទីតាំងចាក់វ៉ាក់សាំង ឬអាចចុះឈ្មោះទុកជាមុនតាមគេហទំព័រ www.vaccine.gov.kh ។ យោងតាមស្ថានភាពជាក់ស្តែង អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធអាចជួយរៀបចំបញ្ជីឈ្មោះប្រជាពលរដ្ឋ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន (ចំពោះកុមារ-យុវវ័យត្រូវមានការយល់ព្រមពីមាតា-បិតាឬអាណាព្យាបាល) រួចចុះឈ្មោះទុកជាមុននៅក្នុងគេហទំព័រ www.vaccine.gov.kh ឬបញ្ជូនបញ្ជីឈ្មោះនោះទៅមន្ត្រីគ្រប់គ្រងទីតាំងចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដែលស្ថិតនៅជិតបំផុត។
- ត្រូវអាន សរសេរបំពេញ និងចុះហត្ថលេខា ឬផ្តិតស្នាមមេដៃស្តាំលើលិខិតយល់ព្រមចាក់វ៉ាក់-សាំងកូវីដ-១៩ ដែលផ្តល់ឱ្យដោយគ្រូពេទ្យ/បុគ្គលិកមានសមត្ថកិច្ចនៅទីតាំងចាក់វ៉ាក់សាំង។ ចំពោះកុមារ-យុវវ័យ មាតា-បិតា ឬអាណាព្យាបាល ត្រូវចុះហត្ថលេខា ឬផ្តិតស្នាមមេដៃស្តាំលើលិខិតយល់ព្រមចាក់វ៉ាក់សាំងកូវីដ-១៩។
- ត្រូវបានអនុញ្ញាតឱ្យចាក់វ៉ាក់សាំង ដោយគ្រូពេទ្យដែលមានភារៈកិច្ចពិនិត្យសុខភាពនៅទីតាំងចាក់វ៉ាក់សាំង។ ដូច្នេះបុគ្គលទៅចាក់វ៉ាក់សាំង ត្រូវបញ្ជាក់ប្រាប់អំពីលក្ខខណ្ឌសុខភាពរបស់ខ្លួនឱ្យបានច្បាស់ ឬសុំប្រឹក្សាយោបល់ជាមួយគ្រូពេទ្យអំពីបញ្ហាសំខាន់ផ្សេងទៀត បើសិនជាមាន ឧ. ដូចជាផលរំខានដែលអាចកើតមានជាយថាហេតុក្រោយការចាក់វ៉ាក់សាំងជាដើម។

**ខ. ក្រុមការងារចាក់វ៉ាក់សាំង៖** ទន្ទឹមគ្នានឹងការអនុវត្តតាមគោលការណ៍ណែនាំបច្ចេកទេស និងនីតិវិធីដែលបានកំណត់ដោយក្រសួងសុខាភិបាល នៅតាមទីតាំងចាក់វ៉ាក់សាំងទាំងអស់ ទាំងសេវាសុខាភិ-បាលសាធារណៈ ទាំងសេវាឯកជន គ្រូពេទ្យ/បុគ្គលិក ដែលមានភារៈកិច្ចផ្តល់ការចាក់វ៉ាក់សាំងត្រូវចិត្តទុកដាក់បន្ថែមលើ៖

- ការពិនិត្យមើលប័ណ្ណចាក់វ៉ាក់សាំងរបស់ពលរដ្ឋដែលទៅចាក់វ៉ាក់សាំង ដើម្បីធានាថាការផ្តល់វ៉ាក់សាំងដូសជំរុញត្រឹមត្រូវតាមគម្លាតពេលវេលា និងតាមរបបចាក់វ៉ាក់សាំងដែលបានកំណត់

ដោយក្រសួងសុខាភិបាល។ ក្នុងករណីមិនទាន់ដល់ពេលវេលាត្រូវចាក់ ត្រូវពន្យល់ប្រាប់ប្រជាពលរដ្ឋឱ្យបានច្បាស់លាស់ និងបញ្ជាក់ពីពេលវេលាដែលត្រូវមកចាក់ដូសជំរុញនេះ ។

- ការពិនិត្យសុខភាពប្រជាពលរដ្ឋទៅចាក់វ៉ាក់សាំងឱ្យបានម៉ត់ចត់ មុននឹងអនុញ្ញាតឱ្យចាក់វ៉ាក់-សាំង។ ក្នុងករណីមិនអាចចាក់វ៉ាក់សាំងបានដោយសារបញ្ហាសុខភាព ត្រូវផ្តល់ការពន្យល់ឱ្យបានច្បាស់លាស់។
- ការកត់ត្រាលើប័ណ្ណចាក់វ៉ាក់សាំងឱ្យបានត្រឹមត្រូវ៖ ពេលវេលា ទីកន្លែង និងប្រភេទវ៉ាក់សាំងដូសជំរុញដែលបានប្រើប្រាស់ និងប្រគល់ជូនប្រជាពលរដ្ឋ ក្រោយពីបានចាក់វ៉ាក់សាំងរួច ដោយប្រើប្រាស់ប័ណ្ណចាក់វ៉ាក់សាំងដែលបានកំណត់ឱ្យប្រើប្រាស់ដោយក្រសួងសុខាភិបាល។

## 3.4 ការកំណត់ និងការរៀបចំទីតាំងចាក់វ៉ាក់សាំង

**ក. ផ្នែកសុខាភិបាលសាធារណៈ៖** ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ប្រព្រឹត្តទៅនៅមូលដ្ឋានសុខា-ភិបាលសាធារណៈ និងទីតាំងចល័តដែលត្រូវបានកំណត់៖

- **នៅមូលដ្ឋានសុខាភិបាលសាធារណៈ** រួមមាន មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ និងមន្ទីរពេទ្យជាតិ ដែលត្រូវបានកំណត់ដោយ គ.វ.ក-១៩ និងមន្ទីរពេទ្យបង្អែករាជធានី-ខេត្ត មន្ទីរពេទ្យបង្អែកក្រុង-ស្រុក-ខណ្ឌ និងមណ្ឌលសុខភាព ដែលត្រូវបានកំណត់ដោយរដ្ឋបាលរាជធានី-ខេត្ត។ ក្នុងករណីចាំបាច់ អាចមាននៅមូលដ្ឋានសុខាភិបាលដែលគ្រប់គ្រងដោយក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ។
- **នៅទីតាំងចល័ត**៖ ក្នុងករណីចាំបាច់ ទីតាំងចល័តសម្រាប់ការចាក់វ៉ាក់សាំងដូសជំរុញ អាចត្រូវបានរៀបចំនៅតាម៖
  - រោងចក្រ-សហគ្រាស ឬទីតាំងអាជីវកម្ម សម្រាប់ការចាក់វ៉ាក់សាំងដូសជំរុញ ជូនបុគ្គលិកកម្មករ-និយោជិត។
  - អង្គភាព/ស្ថាប័នរដ្ឋ ឬទីតាំងសាធារណៈសមស្រប ដែលត្រូវបានកំណត់ដោយ គ.វ.ក-១៩ ឬអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត យោងតាមស្ថានភាពជាក់ស្តែងក្នុងរាជធានី-ខេត្ត នីមួយៗ។

ទីតាំងចល័តគប្បីមានធំទូលាយ ដើម្បីងាយស្រួលក្នុងការអនុវត្តវិធានការ «៣ ការពារ ៣ កុំ» និងស្ថិតនៅជិតមន្ទីរពេទ្យ ដើម្បីផ្តល់សេវាសង្គ្រោះបន្ទាន់ទាន់ពេលវេលា ចំពោះផលរំខានណាមួយដែលអាចកើតមានជាយថាហេតុបន្ទាប់ពីការចាក់វ៉ាក់សាំង។

**ខ. ផ្នែកសុខាភិបាលឯកជន** ត្រូវបានអនុញ្ញាតឱ្យផ្តល់សេវាចាក់វ៉ាក់សាំងកូវីដ-១៩ ដោយរាប់បញ្ចូលទាំងវ៉ាក់សាំងដូសជំរុញ តែនៅទីតាំង/គ្រឹះស្ថានណា ដែលត្រូវបានអនុញ្ញាតដោយក្រសួងសុខាភិបាលប៉ុណ្ណោះ។ ទីតាំង/គ្រឹះស្ថានផ្តល់សេវាចាក់វ៉ាក់សាំងកូវីដ-១៩ ត្រូវបិទផ្សាយព័ត៌មាន ដែលអតិថិជន

ងាយស្រួលមើលឃើញ រួមមានជាអាទិ៍ៈ លិខិតអនុញ្ញាតឱ្យផ្តល់សេវាចាក់វ៉ាក់សាំងកូវីដ-១៩ របស់ក្រសួងសុខាភិបាល ប្រភេទវ៉ាក់សាំងកូវីដ-១៩ ដែលផ្តល់ និងថ្លៃវ៉ាក់សាំងក្នុងមួយដូស។

**គ. ការរៀបចំទីតាំងចាក់វ៉ាក់សាំង និងលំហូរនៃកិច្ចដំណើរការចាក់វ៉ាក់សាំង៖** មូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជន ត្រូវអនុវត្តតាមគោលការណ៍ណែនាំបច្ចេកទេស និងនីតិវិធីដែលបានកំណត់ដោយក្រសួងសុខាភិបាល ដើម្បីធានាឱ្យដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ មានរបៀបរៀបរយនិងសណ្តាប់ធ្នាប់ល្អ រក្សាសុវត្ថិភាពខ្ពស់ ព្រមទាំងទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩។ ទីតាំងចាក់វ៉ាក់សាំងត្រូវរៀបចំឱ្យមានគំនូសបំព្រួញបង្ហាញផ្លូវ ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកមកចាក់វ៉ាក់សាំង និងមានផ្ទាំងរូបភាពអប់រំណែនាំខ្លីៗដែលអ្នកមកចាក់វ៉ាក់សាំងងាយស្រួលមើលឃើញខណៈពេលអង្គុយរង់ចាំ។

## 3.5 កិច្ចសហការរវាងរដ្ឋ និងវិស័យឯកជនក្នុងការចាក់វ៉ាក់សាំងដូសជំរុញ

ការចូលរួមនៃវិស័យឯកជន ក្នុងការងារចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ត្រូវអនុវត្តតាមគោលការណ៍រួម ដូចខាងក្រោម៖

- ប្រើប្រាស់យន្តការពាក់ព័ន្ធដែលមានស្រាប់តាមវិស័យ/អន្តរវិស័យ និងយន្តការពាក់ព័ន្ធចំពោះឱ្យ គ.វ.ក-១៩ សម្រាប់ការពិភាក្សា និងសម្របសម្រួល អំពីការចូលរួមរបស់ម្ចាស់រោងចក្រ-សហគ្រាស និងអាជីវកម្មទាំងអស់ ជាមួយរាជរដ្ឋាភិបាល ក្នុងការចែករំលែកបន្ទុកចំណាយមួយផ្នែក ឬតាមសមាមាត្រសមស្របនៃចំណាយសរុបសម្រាប់ដំណើរការចាក់វ៉ាក់សាំងដូសជំរុញ និងការរៀបចំចាត់ចែងដំណើរចាក់វ៉ាក់សាំងដូសជំរុញជូនបុគ្គលិក កម្មករ-និយោជិតរបស់ខ្លួន។ ចំណាយចាំបាច់សម្រាប់ដំណើរការចាក់វ៉ាក់សាំង រួមមានជាអាទិ៍៖ ថវិកាសម្រាប់ការទិញវ៉ាក់-សាំង សម្ភារបរិក្ខារពេទ្យ សម្ភារអនាម័យ ឧបករណ៍ការពារខ្លួន សម្ភារឧបករណ៍ថែរក្សានិងទុកដាក់វ៉ាក់សាំង ការ-រៀបចំទីតាំង ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត និងអាហារក្រុមការងារចាក់វ៉ាក់សាំងជាដើម។
- ផ្តល់ការអនុញ្ញាតឱ្យនាំចូល ចែកចាយ និងប្រើប្រាស់ តែចំពោះប្រភេទវ៉ាក់សាំងដែលត្រូវបានទទួលស្គាល់ និងអនុញ្ញាតឱ្យប្រើប្រាស់ក្នុងគ្រាបន្ទាន់ ដោយអង្គការសុខភាពពិភពលោក និងដោយក្រសួងសុខាភិបាលកម្ពុជា ប៉ុណ្ណោះ។
- កំណត់បែបបទ និងនីតិវិធី នៃការនាំចូលនិងចែកចាយ និងការផ្តល់សេវាចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ដោយមានអនុលោមភាពស្របតាមលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ/ពិធីសារបច្ចេកទេស ពាក់ព័ន្ធផ្សេងៗ ដែលបានកំណត់ដោយក្រសួងសុខាភិបាលឬអាជ្ញាធរមានសមត្ថ-កិច្ចពាក់ព័ន្ធ។

- ត្រួតពិនិត្យការអនុវត្ត បែបបទ និងនីតិវិធីនៃការនាំចូល និងចែកចាយ និងការផ្ដល់ការចាក់វ៉ាក់សាំងកូវីដ-១៩ ការផ្សព្វផ្សាយ និងភាពសមស្របនៃថ្លៃវ៉ាក់សាំង។

## 3.6 ក្រុមការងារចាក់វ៉ាក់សាំង

ជាទូទៅ ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈក្ដី និង/ឬ នៅតាមទីតាំងចល័តក្ដី ត្រូវធ្វើឡើងដោយក្រុមការងារចាក់វ៉ាក់សាំងដែលជា គ្រូពេទ្យ បុគ្គលិកសុខាភិបាលនៃរដ្ឋបាលរាជធានី-ខេត្ត និងមន្ទីរពេទ្យជាតិ និងក្រុមការងារចាក់វ៉ាក់សាំងរបស់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ។ ក្នុងករណីចាំបាច់ គ.វ.ក-១៩ និងអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងរដ្ឋបាលរាជធានី-ខេត្ត អាចសហការជាមួយក្រសួង-ស្ថាប័ន ដែលមានក្រុមគ្រូពេទ្យ ដូចជាក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា ជាដើម និងជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តក្នុងកិច្ចដំណើរការចាក់វ៉ាក់សាំងដូសជំរុញ។

ចំពោះសេវាសុខាភិបាលឯកជន ក្រុមការងារចាក់វ៉ាក់សាំងកូវីដ-១៩ ត្រូវចុះបញ្ជិកា និងទទួលបានអាជ្ញាបណ្ណវិជ្ជាជីវៈសុខាភិបាល តាមប្រភេទវិជ្ជាជីវៈរបស់ខ្លួន (professional registration and licensing) ជាមួយ/ពី គណៈវិជ្ជាជីវៈរបស់ខ្លួន (ឧ. គណៈគ្រូពេទ្យ, គណៈគិលានុប្បដ្ឋាក-យិកា, គណៈឆ្មប, គណៈឱសថការី និងគណៈទន្តពេទ្យ)។ ក្នុងករណីចាំបាច់ អនុគណៈកម្មការពាក់ព័ន្ធ នៃ គ.វ.ក-១៩ ត្រូវផ្ដល់ការបណ្ដុះបណ្ដាលដល់ក្រុមការងារចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងផ្នែកឯកជន លើទិដ្ឋភាពបច្ចេកទេសសំខាន់ៗ ដូចជាពិធីសារនៃការចាក់វ៉ាក់សាំង ការគ្រប់គ្រងកាកសំណល់ក្រោយការចាក់វ៉ាក់-សាំង ការគ្រប់គ្រងប្រព័ន្ធត្រជាក់ថែរក្សាវ៉ាក់សាំង ការគ្រប់គ្រងទិន្នន័យចាក់វ៉ាក់សាំងតាមប្រព័ន្ធព័ត៌មានវិទ្យា និងការគ្រប់គ្រងផលរំខានក្រោយការចាក់វ៉ាក់សាំង ជាដើម។

## 3.7 ការដឹកនាំ និងគ្រប់គ្រងការងារចាក់វ៉ាក់សាំងកូវីដ-១៩

គ.វ.ក-១៩ ដឹកនាំ គ្រប់គ្រង និងសម្របសម្រួលកិច្ចការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញតាមរយៈការអភិវឌ្ឍ«ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញដើម្បីបង្កើនភាពស៊ាំទប់ទល់នឹងមេរោគកូវីដ-១៩» (ឬហៅថា ផែនការសកម្មភាពចាក់វ៉ាក់សាំងដូសជំរុញ) តាមដានត្រួតពិនិត្យ និងផ្ដល់ការគាំទ្រដល់ការអនុវត្តផែនការសកម្មភាពចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយរាប់បញ្ចូលទាំងការចាក់វ៉ាក់សាំងកូវីដ-១៩ នៅសេវាសុខាភិបាលឯកជនផងដែរ។

អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩រាជធានី-ខេត្ត ត្រូវរៀបចំផែនការសកម្មភាពចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឱ្យមានសង្គតិភាពជាមួយផែនការសកម្មភាពចាក់វ៉ាក់សាំងដូសជំរុញ និងតាមដានត្រួតពិនិត្យមើលវឌ្ឍនភាពនៃការអនុវត្តផែនការ និងដោះស្រាយបញ្ហា

ប្រឈមនានាដែលជួបប្រទះ ឱ្យបានទាន់ពេលវេលានៅក្នុងក្របខ័ណ្ឌនៃយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទូទាំងរាជធានី-ខេត្ត។

សេវាសុខាភិបាលឯកជន ក៏ត្រូវប្រើប្រាស់ផែនការសកម្មភាពចាក់វ៉ាក់សាំងជូសជំរុញ នេះធ្វើជាមូលដ្ឋានសម្រាប់ការរៀបចំចាត់ចែង និងដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ របស់ខ្លួនផងដែរ។

## 3.8 ការគ្រប់គ្រងវ៉ាក់សាំង និងសំណល់ក្រោយការចាក់វ៉ាក់សាំង

ការងារលទ្ធកម្ម ការគ្រប់គ្រង បែងចែក និងផ្គត់ផ្គង់វ៉ាក់សាំង/សម្ភារៈបរិក្ខារ ប្រព្រឹត្តទៅតាមប្រព័ន្ធ និងយន្តការដែលកំពុងមានស្រាប់ ដែលផ្តោតជាចម្បងលើ៖

- ការផ្គត់ផ្គង់ និងបែងចែកវ៉ាក់សាំង និងសម្ភារៈបរិក្ខារ តាមចំនួនវ៉ាក់សាំងដែលមាន និងស្របតាមលក្ខណៈវិនិច្ឆ័យ និងរបបចាក់វ៉ាក់សាំង សម្រាប់ការចាក់វ៉ាក់សាំងជូសជំរុញ ដូចបានចែងនៅក្នុងចំណុច ៣.១ និង ៣.២ ។ អនុគណៈកម្មការចំពោះកិច្ចរាជធានី-ខេត្ត ត្រូវរៀបចំផែនការបែងចែក និងផ្គត់ផ្គង់វ៉ាក់សាំងដែលបានទទួល ពីឃ្លាំងឱសថកណ្តាលទៅកាន់មូលដ្ឋានសុខាភិបាល នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ការគ្រប់គ្រងប្រព័ន្ធត្រជាក់ នៅទីតាំងស្តុកវ៉ាក់សាំង ពេលដឹកជញ្ជូនវ៉ាក់សាំង និងពេលដំណើរការចាក់វ៉ាក់សាំង អនុលោមតាមពិធីសារដែលបានកំណត់ ដើម្បីរក្សាគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពវ៉ាក់សាំង ចៀសវាងការខូចខាត។
- ការគ្រប់គ្រងបញ្ជីសារពើភណ្ឌវ៉ាក់សាំងឱ្យបានត្រឹមត្រូវ ធ្វើបច្ចុប្បន្នភាពបញ្ជីស្តុកវ៉ាក់សាំង ចំនួនវ៉ាក់សាំងប្រើប្រាស់ និងនៅសល់ប្រចាំថ្ងៃនិងរាយការណ៍ទៀងទាត់តាមកាលកំណត់។
- ការគ្រប់គ្រងសំណល់ក្រោយការចាក់វ៉ាក់សាំងបានត្រឹមត្រូវ ដូចជា ម្ជុល សេរ៉ាំង សំណល់ផ្សេងទៀត ជាដើម ដើម្បីការរក្សាបរិស្ថានអនាម័យល្អ និងបង្ការការឆ្លងរោគ តាមរយៈការអនុវត្ត «គោលការណ៍ណែនាំជាតិស្តីពីសុវត្ថិភាពចាក់ថ្នាំបង្ការ និងការគ្រប់គ្រងសំណល់ និងប្រព័ន្ធបោះចោលសំរាមសម្រាប់ កម្មវិធីចាក់ថ្នាំបង្ការ» ។
- គ.វ.ក-១៩ ឬអាជ្ញាធរសុខាភិបាលមានសមត្ថកិច្ច ត្រូវចុះពិនិត្យមើលប្រព័ន្ធត្រជាក់ថែរក្សាវ៉ាក់សាំងនៅតាមក្រុមហ៊ុនដែលអនុញ្ញាតឱ្យនាំចូល និងចែកចាយវ៉ាក់សាំង និងនៅតាមសេវាឯកជនដែលត្រូវបានអនុញ្ញាតឱ្យផ្តល់សេវាចាក់វ៉ាក់សាំងកូវីដ-១៩ ព្រមទាំងពិនិត្យមើលដំណើរការចាក់វ៉ាក់សាំង និងការគ្រប់គ្រងកាកសំណល់ក្រោយការចាក់វ៉ាក់សាំង។

## 3.9 ការអប់រំផ្សព្វផ្សាយនិងតាមដានផលរំខានក្រោយការចាក់វ៉ាក់សាំង

ការប្រាស្រ័យទាក់ទងជាមួយសាធារណៈជន តាមរយៈការអប់រំផ្សព្វផ្សាយ និងការផ្តល់ព័ត៌មានច្បាស់លាស់ និងទាន់ពេល មានតួនាទីសំខាន់ណាស់ ដើម្បីកសាងទំនុករបស់ប្រជាពលរដ្ឋជា គោលដៅមកចាក់វ៉ាក់សាំងកូវីដ-១៩ ដោយរាប់បញ្ចូលទាំងការចាក់វ៉ាក់សាំងដូសជំរុញ បានគ្រប់ៗគ្នា។ សកម្មភាពនៃការងារអប់រំផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ ត្រូវផ្តោតជាចម្បង លើៈ

- រៀបចំព័ត៌មាន ឬសារអប់រំ ឱ្យបានត្រឹមត្រូវ ច្បាស់លាស់ និងងាយស្រួលយល់ ដោយប្រជា-ពលរដ្ឋទូទៅ ហើយប្រើប្រាស់យន្តការផ្សព្វផ្សាយដែលប្រជាពលរដ្ឋភាគច្រើនអាចទទួលបាននូវព័ត៌មាន និងសារទាំងនោះ។
- គ្រប់គ្រង ត្រួតពិនិត្យតាមដាន និងឆ្លើយតប ឬលុបបំបាត់ ជាបន្ទាន់ ចំពោះប្រព័ន្ធផ្សព្វផ្សាយ ឬព័ត៌មានក្លែងក្លាយ ដែលផ្តល់ផលអវិជ្ជមាន ដល់ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងប៉ះពាល់ដល់យុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩។
- បង្កើនការយល់ដឹងដល់ក្រុមការងារចាក់វ៉ាក់សាំង អំពីលក្ខខណ្ឌសុខភាពដែលមិនត្រូវបានអនុញ្ញាតឱ្យចាក់វ៉ាក់សាំង សុវត្ថិភាព និងផលរំខានក្រោយការចាក់វ៉ាក់សាំង។ ក្រុមការងារចាក់វ៉ាក់សាំងត្រូវមានសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ អាចគ្រប់គ្រងករណីផលរំខាន ដែលអាចកើតមានបន្ទាប់ពីការចាក់វ៉ាក់សាំង។
- ពង្រឹងយន្តការតាមដានផលរំខានក្រោយការចាក់វ៉ាក់សាំង ដែលកំពុងដំណើរការបច្ចុប្បន្នឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីផ្តល់ប្រឹក្សាយោបល់ ឆ្លើយតប រាល់ចំងល់នានារបស់មាតា-បិតា និងអាណាព្យាបាលរបស់កុមារ-យុវវ័យ ក៏ដូចជារបស់ប្រជាពលរដ្ឋទូទៅ ទាក់ទង នឹងផលរំខានក្រោយពីការចាក់វ៉ាក់សាំងដែលអាចកើតមានជាយថាហេតុ។
- ក្នុងករណីចាំបាច់ ក្រុមការងារស្រាវជ្រាវផលរំខានក្រោយការចាក់វ៉ាក់សាំងកូវីដ-១៩ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវចុះធ្វើការស្រាវជ្រាវករណីផលរំខានដែលបានរាយ-ការណ៍ ពីសេវាសុខាភិបាលសាធារណៈ និងឯកជន ដោះស្រាយបញ្ហាដែលបានរកឃើញ និងចងក្រងទុកជារបាយការណ៍សម្រាប់ការវាយតម្លៃអំពីផលរំខានក្រោយការចាក់វ៉ាក់សាំង។

## 3.10 ការពិនិត្យតាមដាន វាយតម្លៃ និងការបិទបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំង

**ក. ការពិនិត្យតាមដាន និងវាយតម្លៃការងារចាក់វ៉ាក់សាំង៖** យន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃការងារចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ត្រូវសមាហរណកម្មទៅក្នុងប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃនៃយុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងមូល សំដៅពិនិត្យមើលជាប្រចាំនូវវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅនៃយុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ ដោយរាប់បញ្ចូលទាំងការសម្រេច

គោលដៅនៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដុំទីមួយ និងដុំទី២។ សកម្មភាពនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃផ្ដោតជាចម្បងលើ៖

- ពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យចាក់វ៉ាក់សាំងកូវីដ-១៩ និងសមត្ថភាពស្ថាប័ន ក្នុងការប្រមូលចងក្រង វិភាគ បកស្រាយទិន្នន័យ រៀបចំរបាយការណ៍ និងប្រើប្រាស់របាយការណ៍ ដើម្បីលើកកម្ពស់សកម្មភាពចាក់វ៉ាក់សាំងឱ្យកាន់តែប្រសើរឡើង។
- ពង្រឹងយន្តការត្រួតពិនិត្យតាមដាន និងប្រព័ន្ធរាយការណ៍ទៀងទាត់ តាមកាលកំណត់ ទាំងផ្នែកសុខាភិបាលសាធារណៈ និងឯកជន។
- ដាក់ឱ្យសេវាសុខាភិបាលឯកជន ប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យនៃការចាក់វ៉ាក់សាំងកូវីដ-១៩ និងពិនិត្យទិន្នន័យចាក់វ៉ាក់សាំងកូវីដ-១៩ ដែលរាយការណ៍ ពីសេវាឯកជន និងផ្ដល់យោបល់ត្រឡប់។
- ធានាថាសេវាសុខាភិបាលទាំងសាធារណៈ និងឯកជនបានរាយការណ៍ទៀងទាត់តាមកាលកំណត់។

## ខ. ការបិទបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំង

ដំណើរការបិទបញ្ចប់ការចាក់វ៉ាក់សាំងដូសជំរុញ នៅតាមរាជធានី-ខេត្ត នីមួយៗ និងការឈានទៅបិទបញ្ចប់ការចាក់វ៉ាក់សាំងដូសជំរុញ ក្នុងក្របខណ្ឌទូទាំងប្រទេស ត្រូវអនុវត្តតាមស្មារតីនៃ«សេចក្ដីណែនាំស្ដីពីការពង្រឹងការអនុវត្តយុទ្ធនាការជាតិចាក់វ៉ាក់សាំងដុំទី១» របស់រាជរដ្ឋាភិបាលលេខ ០៦ សណន ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០២១ ដូចខាងក្រោមនេះ៖

- រដ្ឋបាលរាជធានី-ខេត្ត ត្រូវធ្វើបច្ចុប្បន្នកម្មចំនួនប្រជាជនគោលដៅ ក្នុងរាជធានី-ខេត្តនីមួយៗ និងផ្ទៀងផ្ទាត់ឱ្យបានច្បាស់លាស់នូវ ចំនួនជាក់ស្ដែងនៃប្រជាជនដែលបានចាក់វ៉ាក់សាំងដូសជំរុញ និងប្រជាជនដែលមិនទាន់បានចាក់។ ជាគោលការណ៍រួម រាជធានី-ខេត្ត ដែលសម្រេចបានអត្រានៃការចាក់វ៉ាក់សាំងដូសជំរុញ លើសពី ៩០% នៃប្រជាជនគោលដៅ ត្រូវធ្វើការពិនិត្យវាយតម្លៃអំពីលទ្ធភាពសម្រាប់ការបិទបញ្ចប់យុទ្ធនាការក្នុងរាជធានី-ខេត្ត របស់ខ្លួន។
- រដ្ឋបាលរាជធានី-ខេត្ត ត្រូវផ្ញើលិខិតស្នើសុំបិទបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដូស-ជំរុញ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ពិនិត្យវាយតម្លៃយុទ្ធនាការចាក់វ៉ាក់សាំងដូសជំរុញនៅក្នុងរាជធានី-ខេត្តរបស់ខ្លួន មកកាន់ គ.វ.ក-១៩ ដើម្បីពិនិត្យនិងផ្ដល់យោបល់ ឬពិភាក្សាបន្ថែមជាមួយរដ្ឋបាលរាជធានី-ខេត្ត នៅក្នុងករណីចាំបាច់។
- គ.វ.ក-១៩ នឹងស្នើសុំយោបល់ពីគណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធជំងឺកូវីដ-១៩ លើសំណើសុំបិទបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញរបស់រដ្ឋបាលរាជធានី-ខេត្ត មុនពេលលើកសំណើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពី **សម្ដេចតេជោនាយករដ្ឋមន្ត្រី**។

- រដ្ឋបាលរាជធានី-ខេត្ត ត្រូវរក្សាទុកកន្លែងចាក់វ៉ាក់សាំងមួយចំនួន នៅតាមមូលដ្ឋានសុខាភិបាល និងផ្សព្វផ្សាយព័ត៌មាន/ជូនដំណឹងឱ្យបានទូលំទូលាយជូនប្រជាពលរដ្ឋ ក្នុងរាជធានី-ខេត្តរបស់ខ្លួន សម្រាប់បន្តការចាក់វ៉ាក់សាំងដូសជំរុញជូនប្រជាពលរដ្ឋ ដែលមិនទាន់បានចាក់វ៉ាក់សាំងដូសជំរុញ ក្រោយពេលប្រកាសបិទបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ។

# 4 ការអនុវត្តផែនការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ

ជារួម ការអនុវត្តផែនការចាក់វ៉ាក់សាំងដូស ជំរុញត្រូវអនុវត្តតាមខ្លឹមសារនៃ «សេចក្តីណែនាំស្តីពីការពង្រឹងការអនុវត្តយុទ្ធនាការជាតិចាក់វ៉ាក់សាំងជុំទី១» របស់រាជរដ្ឋាភិបាលលេខ ០៦ សណន ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២១ ។ អភិក្រម "ផ្កាវីក" ជាត្រូវបានប្រើប្រាស់ជាអភិក្រមគោល សម្រាប់កិច្ចដំណើរការចាក់វ៉ាក់សាំងដូសជំរុញ ដោយប្រព្រឹត្តទៅតាម ២ ដំហាន៖

- ដំហានទី១៖ ចាប់ផ្តើមនៅក្នុងខែសីហា ឆ្នាំ២០២១
- ដំហានទី២៖ ចាប់ផ្តើមនៅក្នុងខែកញ្ញា ឆ្នាំ២០២១ ដល់ខែមិថុនា ឆ្នាំ២០២២

គួរកត់សម្គាល់ថា ការចាក់វ៉ាក់សាំងដូសជំរុញ ដល់ក្រុមកុមារ-យុវវ័យអាយុពី១២ឆ្នាំ ដល់ក្រោម ១៨-ឆ្នាំ ដែលបានចាក់វ៉ាក់សាំងដូសទី២ រួចរាល់នៅដំណាច់ខែសីហា ឆ្នាំ២០២១ អាចចាប់ផ្តើមចាក់វ៉ាក់សាំងដូសជំរុញបាននៅក្នុងខែកុម្ភៈ ឆ្នាំ២០២២ និងខែបន្តបន្ទាប់ នៅក្រោមលក្ខខណ្ឌនៃគម្លាតពេលវេលា ៦ ខែ រវាងការចាក់ដូសទី២ រួច និងការចាក់ដូសជំរុញ។ ម្យ៉ាងវិញទៀត ការចាក់វ៉ាក់សាំងដូសជំរុញដល់ក្រុមកុមារ-យុវវ័យ នឹងអាចចាប់ផ្តើមបានតាមពេលវេលាខាងលើ អាស្រ័យលើអនុសាសន៍របស់ក្រុមការងារជំនាញរបស់ក្រសួងសុខាភិបាល ដែលផ្អែកលើលទ្ធផលនៃការសិក្សា/វិភាគអំពីប្រសិទ្ធភាពនៃវ៉ាក់សាំងកូវីដ-១៩ ២ ដូស លើក្រុមនេះ។

## 4.1 ដំហាននៃការចាក់វ៉ាក់សាំងដូសជំរុញ

### ក. ដំហានទី១៖ ចាប់ផ្តើមនៅក្នុងខែសីហា ឆ្នាំ២០២១

នៅក្នុងដំហានទី១ ការចាក់វ៉ាក់សាំងដូសជំរុញចាប់ផ្តើមលើក្រុមប្រជាពលរដ្ឋគោលដៅជាអាទិ-ភាព ដែលបានចាក់វ៉ាក់សាំងដូសទី២ ប្រភេទ Sinopharm និង Sinovac រួចរាល់ ចាប់ពី ៤ខែ ឡើង នៅក្នុងខេត្ត ៧ នៅជាប់ព្រំដែនភាគខាងលិចប្រទេស (ខេត្តបន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន ពោធិសាត់ កោះកុង ឧត្តរ-មានជ័យ និងព្រះវិហារ) បន្ទាប់មកបន្តលើក្រុមគោលដៅជាអាទិភាព នៅក្នុងរាជធានី-ខេត្ត ទាំងអស់ទូទាំងប្រទេស (រូបភាព ៤.១) ។

**រូបភាព ៤.១. ជំហានទី១៖ ចាប់ផ្តើមពីខែសីហា ឆ្នាំ២០២១ ពីខេត្តជាប់ព្រំដែនភាគខាងលិច**




- ចាប់ផ្តើមពី ខេត្ត ៧ ជាប់ព្រំដែនភាគខាងលិច
- បន្ទាប់មកនៅរាជធានី-ខេត្ត ទាំង២៥

ជារួម ប្រជាពលរដ្ឋដែលបានចាក់វ៉ាក់សាំង Sinopharm និង Sinovac ដូសទី២ រួចរាល់ ក្នុងជុំទី១ និងមានលក្ខណៈសម្បត្តិសមស្របតាមលក្ខខណ្ឌបច្ចេកទេសសម្រាប់ការចាក់ដូសជំរុញ។

**ក្រុមគោលដៅអាទិភាពដំបូងគេនៅខេត្តជាប់ព្រំដែនភាគខាងលិច៖**

- ក្រុមគ្រូពេទ្យ បុគ្គលិកសុខាភិបាលសាធារណៈ និងឯកជនជួរមុខ
- មន្ត្រីរាជការ មន្ត្រីអន្តរាគមន៍ជួរមុខ(តាមព្រំដែន មណ្ឌលចត្តាឡីស័ក មណ្ឌលព្យាបាលអ្នកជំងឺកូវីដ-១៩)
- កងទ័ព គ្រួសារកងទ័ព នគរបាលជាតិ អតីតយុទ្ធជន

**ក្រុមគោលដៅអាទិភាពបន្ទាប់ នៅរាជធានី-ខេត្ត ទាំង ២៥៖**

- ក្រុមគ្រូពេទ្យ បុគ្គលិកសុខាភិបាលសាធារណៈ និងឯកជន
- មន្ត្រីអន្តរាគមន៍ កងទ័ព គ្រួសារកងទ័ព នគរបាលជាតិ អតីតយុទ្ធជន
- មន្ត្រីរាជការស៊ីវិល ព្រមទាំងមន្ត្រីជាប់កិច្ចសន្យា នៅថ្នាក់ជាតិ (ក្រសួង-ស្ថាប័ន/អង្គភាព អាជ្ញាធរជាតិ គ្រឹះស្ថានសាធារណៈ) និងថ្នាក់ក្រោមជាតិ
- មន្ត្រីស្ថាប័ននីតិបញ្ញត្តិ និងតុលា

### ខ. ជំហានទី២៖ ចាប់ផ្ដើមពីខែកញ្ញា ឆ្នាំ២០២១ ដល់ខែមិថុនា ឆ្នាំ២០២២

នៅក្នុងជំហានទី២ ការចាក់វ៉ាក់សាំងដូសជំរុញ អនុវត្តតាមអភិក្រម "ផ្ការីក" ដោយចាប់ផ្ដើមចេញដំណើរពីរាជធានីភ្នំពេញ ខេត្តកណ្ដាល ព្រះសីហនុ និងកោះកុង និងតាមក្រុង-ស្រុក-ខណ្ឌ នៃខេត្តផ្សេងទៀត ជាបន្តបន្ទាប់ ដល់ប្រជាពលរដ្ឋគោលដៅបានចាក់វ៉ាក់សាំងដូសទី២ រួចរាល់ ក្នុងជុំទី១ និងមានលក្ខណៈសម្បត្តិសមស្របតាមលក្ខខណ្ឌបច្ចេកទេសសម្រាប់ការចាក់ដូសជំរុញ(រូបភាព៤.២)

**រូបភាព ៤.២. ជំហានទី២៖ ចាប់ផ្ដើមពីខែកញ្ញាឆ្នាំ២០២១ - ខែមិថុនា ឆ្នាំ២០២២ ក្នុងរាជធានី-ខេត្តទាំង២៥**




**ប្រជាពលរដ្ឋគោលដៅ៖** ប្រជាពលរដ្ឋដទៃទៀតដែលបានចាក់វ៉ាក់សាំងដូសទី២ រួចរាល់ ក្នុងជុំទី១ និងមានលក្ខណៈសម្បត្តិសមស្របតាមលក្ខខណ្ឌបច្ចេកទេសសម្រាប់ការចាក់ដូសជំរុញ។ ក្នុងករណីចំនួនវ៉ាក់សាំងមានកម្រិត ត្រូវផ្ដល់អាទិភាពមុនគេដល់ប្រជាជនអាយុចាប់ពី៦០ឆ្នាំឡើង, បុគ្គលិក កម្មករ-និយោជិត ជួរមុខក្នុងវិស័យឯកជន (ឧ. កម្មករប្រមូលសម្រាម បុគ្គលិកសិក្សាអប់រំ អគ្គិសនី ទឹកស្អាត រោងចក្រសហគ្រាសផ្នែកសេវាកម្មចាំបាច់នានា ក្នុងតំបន់ប្រឈមហានិភ័យខ្ពស់ ជាដើម)។

## 4.2 តម្រូវការវ៉ាក់សាំង

និយាយជារួម វ៉ាក់សាំងដែលត្រូវការសម្រាប់ដូសជំរុញមានចំនួន ១២.៧៦៣.៣៨១ ដូស ពោល គឺស្មើនឹងចំនួនប្រជាពលរដ្ឋគោលដៅអាយុពី១២ឆ្នាំឡើង, ហើយចំនួនវ៉ាក់សាំងដែលត្រូវការនេះទៀតសោតក៏អាស្រ័យជាចម្បងចំនួនជាក់ស្តែងនៃប្រជាពលរដ្ឋគោលដៅ ដែលបានចាក់វ៉ាក់សាំងពេញលេញតាមរបបចាក់វ៉ាក់សាំងមូលដ្ឋាន ដែលបានកំណត់។ និយាយដោយឡែកចំនួនវ៉ាក់សាំងជាក់-ស្តែងប្រភេទ mRNA viral vector ឬ inactive virus ដែលត្រូវការគឺអាស្រ័យលើប្រភេទវ៉ាក់សាំង ដែលអាចរកបាន និងរបបចាក់វ៉ាក់សាំងសម្រាប់ដូសជំរុញ(របបចាក់វ៉ាក់សាំងចម្រុះនិងសម្រុងគ្នានិង/ឬរបបចាក់វ៉ាក់សាំងប្រភេទតែមួយ)។

ប្រទេសកម្ពុជាប្រើប្រាស់ភាគច្រើនលើសលប់ នូវប្រភេទវ៉ាក់សាំង Sinopharm និង Sinovac ជាវ៉ាក់សាំងមូលដ្ឋាន ហើយវ៉ាក់សាំងប្រភេទនេះក៏មានប្រសិទ្ធភាពសម្រាប់ជាដូសជំរុញ ដូច្នេះការរៀបចំផែនការលទ្ធកម្មវ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ត្រូវបន្តយកប្រភពផ្គត់ផ្គង់ពីប្រទេសចិនធ្វើជាបង្អែកផ្នែកយុទ្ធសាស្ត ហើយប្រភពផ្សេងទៀតនៅបន្តជាប្រភពគាំទ្រសម្រាប់ផែនការចាក់វ៉ាក់សាំងកូវីដ-១៩ របស់ប្រទេសកម្ពុជា។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០១ [illegible]

# សេចក្តីប្រកាស
## ស្តីពី
## គោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ជូនសជំរុញ

រាជរដ្ឋាភិបាលបានចាត់ទុកគោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ គឺជាយុទ្ធសាស្ត្រគន្លឹះដ៏សំខាន់មួយ និងជាខ្សែក្រវាត់ការពារទី១ សំខាន់ជាងគេ ដើម្បីការពារអាយុជីវិតប្រជាជន ក៏ដូចជាដើម្បីបង្កើតឱ្យបាននូវភាពស៊ាំក្នុងសហគមន៍ទប់ទល់នឹងមេរោគកូវីដ-១៩ សំដៅឈានឆ្ពោះទៅបើកដំណើរការប្រទេសជាតិពេញលេញឡើងវិញលើគ្រប់វិស័យ និងការរស់នៅជាមួយនឹងជំងឺនេះតាមគន្លងប្រក្រតីភាពថ្មី។ គិតហេតុមកដល់ពេលបច្ចុប្បន្ន, យុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាជនដោយឥតគិតថ្លៃ និងតាមគោលការណ៍ស្ម័គ្រចិត្ត សម្រេចបាននូវវឌ្ឍនភាពយ៉ាងល្អប្រសើរ ដែលមានប្រជាពលរដ្ឋអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ចំនួនប្រមាណ ៨៨% ធៀបនឹងគោលដៅចំនួន ១០ លាននាក់ ហើយកុមារ និងយុវជនអាយុចាប់ពី ១២ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ចំនួនប្រមាណ ៥៦% ធៀបនឹងគោលដៅចំនួនប្រមាណជិត ២ លាននាក់ បានទទួលការចាក់វ៉ាក់សាំងកូវីដ-១៩។ ផ្អែកលើវឌ្ឍនភាពដ៏ល្អប្រសើរនេះ និងដោយសារមានការគាំទ្រ និងចូលរួមយ៉ាងសកម្ម និងទូលំទូលាយពីសំណាក់ប្រជាជននៅគ្រប់មជ្ឈដ្ឋាន, យុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ ជុំទី១ នេះ ត្រូវបានរំពឹងថានឹងអាចបញ្ចប់នៅចុងខែតុលា ឬដើមខែវិច្ឆិកា ឆ្នាំ២០២១ ខាងមុខនេះ មុនផែនការដែលបានគ្រោងទុក។

ការចាក់វ៉ាក់សាំងកូវីដ-១៩ បានឆាប់រហ័ស និងទាន់ពេល បានជួយសង្គ្រោះអាយុជីវិតប្រជាជនកម្ពុជាជាច្រើន តាមរយៈការកាត់បន្ថយករណីឆ្លង, ករណីធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ និងករណីស្លាប់ដោយជំងឺកូវីដ-១៩ និងបានបញ្ចៀសកម្ពុជាពីគ្រោះមហន្តរាយដែលបណ្តាលមកពីជំងឺកូវីដ-១៩ នេះ ព្រមទាំងធ្វើឱ្យសភាពការណ៍បច្ចុប្បន្ននៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន។ ប៉ុន្តែ ការរកឃើញជាបន្តបន្ទាប់ក្នុងសហគមន៍នៃមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta) បាននាំមកនូវបញ្ហាប្រឈមថ្មីមួយទៀតសម្រាប់ព្រះរាជាណាចក្រកម្ពុជា ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដោយសារមេរោគបំប្លែងខ្លួនប្រភេទថ្មីនេះ មានសមត្ថភាពចម្លងបានលឿនជាងមុន និងមានកម្រិតគ្រោះថ្នាក់ធ្ងន់ធ្ងរ ព្រមទាំងអាចកាត់បន្ថយប្រសិទ្ធភាពនៃវ៉ាក់សាំងបាន។ ទន្ទឹមនឹងនេះ ភស្តុតាងបែបវិទ្យាសាស្ត្រដែលបានលើកឡើងនៅក្នុងឯកសារសិក្សាស្រាវជ្រាវពីប្រទេសជាច្រើន បានបង្ហាញថា ក្រោយពេលចាក់វ៉ាក់សាំងមូលដ្ឋានគ្រប់ដូសរួចហើយ, កម្រិតភាពស៊ាំប្រឆាំងនឹងមេរោគកូវីដ-១៩ អាចស្ថិតនៅរយៈពេលប្រមាណពី ៦ ទៅ ៨ ខែ សម្រាប់ករណីទូទៅ

និងអាចខ្លីជាងនេះសម្រាប់ក្រុមមនុស្សវ័យចាស់ និងអ្នកមានប្រព័ន្ធការពារខ្សោយ ហើយការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ អាចបង្កើនភាពឆ្លើយតបនៃអង្គបដិបក្ខនៃប្រព័ន្ធការពារក្នុងខ្លួន ឱ្យកាន់តែប្រសើរឡើងថែមទៀត ដើម្បីប្រឆាំងនឹងមេរោគកូវីដ-១៩ ប្រភេទដែលតា (Delta) និងប្រភេទបំប្លែងខ្លួនថ្មីផ្សេងទៀត។ ផ្អែកលើទឡ្ហីករណ៍វិទ្យាសាស្ត្រខាងលើនេះ និងយោងតាមប្រភពព័ត៌មានដែលផ្សព្វផ្សាយជាសាធារណៈ ប្រទេសជាច្រើន រួមមាន អ៊ីស្រាអែល, សហរដ្ឋអាមេរិក, ហុងគ្រី, ឥណ្ឌូនេស៊ី, អារ៉ាប់អេមីរ៉ាត, រុស្ស៊ី, ឈីលី, បារាំង, អង់គ្លេស, អាល្លឺម៉ង់, អូទ្រីស ជាដើម បានសម្រេចចិត្ត ឬគ្រោងចាក់វ៉ាក់សាំងដូសជំរុញនេះ ដើម្បីទប់ទល់ជាមួយនឹងការរាលដាលទ្រង់ទ្រាយធំនៃមេរោគកូវីដ-១៩ ប្រភេទដែលតា (Delta) និងប្រភេទបំប្លែងខ្លួនថ្មីផ្សេងទៀត។ សម្រាប់ព្រះរាជាណាចក្រកម្ពុជា, ទន្ទឹមនឹងការសម្រេចប្រើប្រាស់វ៉ាក់សាំងប្រភេទ AstraZeneca ដើម្បីចាក់ជាដូសជំរុញដល់មន្ត្រីសុខាភិបាល និងមន្ត្រីបម្រើការជួរមុខក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅតាមតំបន់ដែលមានហានិភ័យខ្ពស់នៃការឆ្លងរាលដាលនៃមេរោគកូវីដ-១៩ ប្រភេទដែលតា (Delta) កាលពីដើមខែសីហា ឆ្នាំ២០២១ កន្លងទៅ, ក្រុមការងារជំនាញក៏បានសិក្សាស្រាវជ្រាវរកឃើញដែរថា ការចាក់ដូសជំរុញនេះ ទោះបីប្រើប្រាស់វ៉ាក់សាំងប្រភេទដូចគ្នា ឬវ៉ាក់សាំងប្រភេទខុសគ្នាក៏ដោយ មិនបង្កឱ្យមានផលវិបាកច្រើនលើសពីផលវិបាកដែលបង្កឡើងដោយវ៉ាក់សាំងនីមួយៗជាធម្មតានោះទេ ហើយការចាក់ដូសជំរុញនេះថែមទាំងអាចបង្កើនបាននូវប្រព័ន្ធការពាររាងកាយកាន់តែរឹងមាំ ក្នុងការទប់ទល់នឹងមេរោគកូវីដ-១៩ ប្រភេទដែលតា (Delta) និងប្រភេទបំប្លែងខ្លួនថ្មីផ្សេងទៀត។

ផ្អែកតាមការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រខាងលើ និងក្នុងគោលបំណងបង្កើតឱ្យបានឆាប់រហ័សនូវ "**ភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយ**" ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការពារអាយុជីវិតប្រជាជនពីមេរោគកូវីដ-១៩ ពិសេស ប្រភេទដែលតា (Delta) ឬប្រភេទបំប្លែងខ្លួនថ្មីផ្សេងទៀត ក៏ដូចជា ដើម្បីត្រៀមលក្ខណៈឈានឆ្ពោះទៅកាន់ផែនការនៃការបើកដំណើរការប្រទេសពេញលេញឡើងវិញលើគ្រប់វិស័យ និងការរស់នៅជាមួយនឹងវត្តមានជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី, រាជរដ្ឋាភិបាលសម្រេចប្រកាសដាក់ចេញនូវ "**គោលនយោបាយចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ**" ដល់ប្រជាជនទូទៅចាប់ពីអាយុ ១២ ឆ្នាំឡើងទៅ ចាប់ពីខែសីហា ឆ្នាំ២០២១ នេះ ដល់អំឡុងពាក់កណ្តាលឆ្នាំ ២០២២ អាស្រ័យលើលទ្ធភាពនៃការស្វែងរក និងទទួលបានវ៉ាក់សាំងកូវីដ-១៩ ដោយអនុវត្តតាមគោលការណ៍ ដូចខាងក្រោម៖

**១-គោលការណ៍ស្ម័គ្រចិត្ត៖** រាជរដ្ឋាភិបាលនៅតែបន្តអនុវត្ត "**គោលការណ៍ស្ម័គ្រចិត្ត**" ដដែល ចំពោះការចាក់វ៉ាក់សាំងដូសជំរុញនេះជូនដល់ប្រជាជន។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏បន្តលើកទឹកចិត្តដល់ប្រជាជនដែលមានលក្ខណៈសម្បត្តិសមស្របតាមលក្ខខណ្ឌបច្ចេកទេសដែលបានចាក់វ៉ាក់សាំងជុំទី១ រួច មកទទួលយកវ៉ាក់សាំងដូសជំរុញនេះឱ្យបានគ្រប់ៗគ្នា ដើម្បីជួយបង្កើនភាពឆ្លើយតបនៃអង្គបដិបក្ខនៃប្រព័ន្ធការពារក្នុងខ្លួនឱ្យកាន់តែប្រសើរឡើងប្រឆាំងនឹងមេរោគកូវីដ-១៩ ជាពិសេស ទប់ទល់នឹងមេរោគបំប្លែងខ្លួនថ្មី ប្រភេទដែលតា (Delta) និងប្រភេទបំប្លែងខ្លួនថ្មីផ្សេងទៀត ដើម្បីការពារអាយុជីវិតខ្លួនឯង និងក្រុមគ្រួសារ ព្រមទាំងបង្កើតឱ្យបាននូវ "**ភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយ**" សម្រាប់ព្រះរាជាណាចក្រកម្ពុជា។

**២-គោលការណ៍ឥតគិតថ្លៃ៖** ជារួម រាជរដ្ឋាភិបាលបន្តផ្តល់ការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញនេះ

ជូនប្រជាជនដោយឥតគិតថ្លៃ ដូចការចាក់វ៉ាក់សាំងនៅជុំទី១ ដែរ។ ទន្ទឹមនេះ ដើម្បីបង្កើនល្បឿននៃការចាក់វ៉ាក់សាំងដូសជំរុញនេះ ក៏ដូចជាដើម្បីកាត់បន្ថយបន្ទុកចំណាយថវិកាជាតិ, រាជរដ្ឋាភិបាលលើកទឹកចិត្ត និងអំពាវនាវដល់ប្រជាជនដែលមានលទ្ធភាពគ្រប់គ្រាន់ ឱ្យទៅទទួលយកការចាក់វ៉ាក់សាំងដូសជំរុញនេះ នៅតាមគ្រឹះស្ថានសុខាភិបាលឯកជន ដែលទទួលបានការអនុញ្ញាតឱ្យផ្តល់សេវាចាក់វ៉ាក់សាំងកូវីដ-១៩ នេះ។ ដោយឡែក បណ្តារោងចក្រ-សហគ្រាស និងម្ចាស់អាជីវកម្មទាំងអស់ ក៏ត្រូវបានលើកទឹកចិត្តឱ្យចូលរួមចំណែកចែករំលែកបន្ទុកចំណាយជាមួយរាជរដ្ឋាភិបាល ក្នុងការផ្តល់ការចាក់វ៉ាក់សាំងដូសជំរុញនេះដល់បុគ្គលិក និងកម្មករ-និយោជិតរបស់ខ្លួនឱ្យបានគ្រប់គ្នា ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ នៅតាមរោងចក្រ-សហគ្រាស និងទីតាំងអាជីវកម្ម និងធានាបាននូវសុវត្ថិភាព និងនិរន្តភាពនៃកិច្ចដំណើរការផលិតកម្មជាប្រក្រតីនៅក្នុងរោងចក្រ-សហគ្រាស ឬអាជីវកម្មរបស់ខ្លួន។ រាជរដ្ឋាភិបាលនឹងរៀបចំឱ្យមានយន្តការ ដើម្បីសម្របសម្រួលជាមួយវិស័យឯកជន និងតួអង្គពាក់ព័ន្ធ ទាំងលើការរួមចំណែករបស់រោងចក្រ-សហគ្រាស និងម្ចាស់អាជីវកម្មធំៗ ក្នុងការជួយរ៉ាប់រងចំណាយ ដើម្បីចាក់វ៉ាក់សាំងដូសជំរុញដល់បុគ្គលិក និងកម្មករ-និយោជិតរបស់ខ្លួន ទាំងលើការជួយគាំទ្រដល់វិស័យឯកជនក្នុងការនាំចូល និងចែកចាយវ៉ាក់សាំងកូវីដ-១៩ និងផ្តល់សេវាចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាពលរដ្ឋកម្ពុជាក្នុងថ្លៃសមស្រប។

**៣-ការធ្វើអាទិភាវូបនីយកម្មនៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ទៅលើក្រុមមនុស្ស និងតាមទីតាំងភូមិសាស្ត្រ៖** ការចាក់វ៉ាក់សាំងដូសជំរុញនេះ ត្រូវផ្តើមចេញពីក្រុមមន្ត្រីសុខាភិបាល និងមន្ត្រីបម្រើការជួរមុខក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងចាប់ផ្តើមពីតំបន់ដែលមានហានិភ័យខ្ពស់, ប្រជាពលរដ្ឋដែលមានអាយុចាប់ពី ៦០ ឆ្នាំឡើងទៅ និងប្រជាពលរដ្ឋដែលមានប្រព័ន្ធការពាររាងកាយខ្សោយ មុននឹងបន្តទៅចាក់ជូនប្រជាពលរដ្ឋទូទៅ ស្របតាមអភិក្រម **"ផ្ការីក"** ដូចដែលបានអនុវត្តសម្រាប់យុទ្ធនាការជាតិចាក់វ៉ាក់សាំងកូវីដ-១៩ នៅជុំទី១ ដោយផ្តើមចេញពីរាជធានីភ្នំពេញ, ខេត្តកណ្តាល និងបន្តទៅកាន់បណ្តាខេត្តនានាទូទាំងប្រទេស។

**៤-ការធានាប្រសិទ្ធភាព និងសុវត្ថិភាពនៃការចាក់វ៉ាក់សាំងដូសជំរុញ៖** ដើម្បីធានាបាននូវប្រសិទ្ធភាព និងសុវត្ថិភាពនៃការវ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ, ក្រសួងសុខាភិបាល និងយន្តការដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តនូវគោលការណ៍ ដូចខាងក្រោម៖

- ផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់ជាវ៉ាក់សាំងដូសជំរុញ តែចំពោះប្រភេទវ៉ាក់សាំងកូវីដ-១៩ ដែលត្រូវបានទទួលស្គាល់ និងអនុញ្ញាតឱ្យប្រើប្រាស់ក្នុងគ្រាបន្ទាន់ដោយអង្គការសុខភាពពិភពលោក និងដោយក្រសួងសុខាភិបាលកម្ពុជាប៉ុណ្ណោះ។

- កំណត់អំពីប្រភេទវ៉ាក់សាំងសម្រាប់ប្រើប្រាស់ជាដូសជំរុញ សម្រាប់សម្រួលដល់ការស្វះស្វែងរកវ៉ាក់សាំង និងធានាបាននូវការផ្តល់ការចាក់វ៉ាក់សាំងដូសជំរុញនេះដោយយន្តការពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលជូនដល់ប្រជាជន។

- កំណត់អំពីរបបនៃការចាក់វ៉ាក់សាំងដូសជំរុញ ទាំងរបបនៃការចាក់វ៉ាក់សាំងប្រភេទចម្រុះ (Heterologous Vaccination Regiment) ទាំងរបបនៃការចាក់វ៉ាក់សាំងប្រភេទតែមួយដូចគ្នា (Monologues Vaccination Regiment) ព្រមទាំងធ្វើការណែនាំដល់សេវាសុខាភិបាលឯកជនអំពីរបបនៃការចាក់វ៉ាក់សាំង

ដូសជំរុញនេះជូនដល់ប្រជាជន។ ទន្ទឹមនេះ ក្រសួងសុខាភិបាលត្រូវបន្តសិក្សាស្រាវជ្រាវ និងធ្វើបច្ចុប្បន្នកម្ម ជាប្រចាំអំពីរបបចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ, ប្រភេទវ៉ាក់សាំងដែលអាចប្រើជាដូសជំរុញ និងគម្លាត ពេលវេលានៃការចាក់ដូសជំរុញនេះ ហើយធ្វើការផ្សព្វផ្សាយព័ត៌មាន និងជូនដំណឹងដល់សេវាសុខាភិបាល និងសាធារណជនឱ្យបានទូលំទូលាយ។

- ជូនដំណឹងដល់សាធារណជនអំពីរបបនៃការចាក់វ៉ាក់សាំង និងណែនាំអំពីរបៀបនៃការទទួល បានការចាក់វ៉ាក់សាំងដូសជំរុញនេះ ដោយរួមទាំងប្រភេទវ៉ាក់សាំងដែលអាចប្រើជាដូសជំរុញ, គម្លាតពេលវេលា នៃការចាក់ដូសជំរុញ និងរបបនៃការចាក់វ៉ាក់សាំងដូសជំរុញ។

**៥-យន្តការអនុវត្តគោលនយោបាយ៖** ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយចាក់វ៉ាក់សាំង ដូសជំរុញនេះ, រាជរដ្ឋាភិបាលសម្រេចប្រគល់ភារកិច្ចជូនដល់ក្រសួង-ស្ថាប័ន និងយន្តការដែលមានការពាក់ព័ន្ធ ដូចខាងក្រោម៖

- គណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវដឹកនាំសម្របសម្រួលការងារ រួម និងតាមដានត្រួតពិនិត្យការអនុវត្តសេចក្តីប្រកាសគោលនយោបាយនេះឱ្យមានប្រសិទ្ធភាព។

- គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ត្រូវរៀបចំផែនការ សកម្មភាពចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ និងត្រូវខិតខំដឹកនាំសម្របសម្រួលការអនុវត្តផែនការនេះឱ្យបាន ចប់សព្វគ្រប់តាមការគ្រោងនៅក្នុងអំឡុងពាក់កណ្តាលឆ្នាំ ២០២២ ខាងមុខ ព្រមទាំងត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងផ្តល់ការគាំទ្រចាំបាច់នានាដល់ការអនុវត្តផែនការសកម្មភាពចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយរាប់បញ្ចូលទាំងការចាក់វ៉ាក់សាំងកូវីដ-១៩ នៅសេវាសុខាភិបាល ឯកជនផងដែរ។

- គណៈកម្មការចំពោះកិច្ចទទួលបន្ទុកលទ្ធកម្មវ៉ាក់សាំងកូវីដ-១៩ ត្រូវរៀបចំផែនការលទ្ធកម្ម បម្រើឱ្យផែនការសកម្មភាពចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ និងស្វះស្វែងរកប្រភពផ្គត់ផ្គង់វ៉ាក់សាំង តាមរយៈ យន្តការទ្វេភាគី និងពហុភាគី ដើម្បីត្រៀមបម្រុងវ៉ាក់សាំងទុកជាមុនឱ្យបានគ្រប់គ្រាន់ សម្រាប់ការចាក់ដូសជំរុញ នេះ ស្របតាមយុទ្ធសាស្ត្រវ៉ាក់សាំងរបស់រាជរដ្ឋាភិបាល និងតាមផែនការសកម្មភាព ដែលរៀបចំដោយគណៈ- កម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស។ ដោយសារប្រជាជនកម្ពុជាភាគច្រើន លើសលប់បានទទួលការចាក់វ៉ាក់សាំងប្រភេទ Sinopharm និង Sinovac ជាវ៉ាក់សាំងមូលដ្ឋាន ហើយ ដោយសារវ៉ាក់សាំងប្រភេទនេះ ត្រូវបានរកឃើញដោយក្រុមការងារជំនាញថា អាចជាជម្រើសមានប្រសិទ្ធភាព មួយក្នុងការប្រើប្រាស់សម្រាប់ជាដូសជំរុញ ទាំងចំពោះអ្នកដែលបានចាក់វ៉ាក់សាំងមូលដ្ឋានប្រភេទ Sinopharm ឬ Sinovac ទាំងចំពោះអ្នកដែលបានចាក់វ៉ាក់សាំងមូលដ្ឋានប្រភេទ AstraZeneca ឬ Johnson & Johnson, ដូច្នេះ ក្នុងការរៀបចំផែនការលទ្ធកម្មវ៉ាក់សាំងកូវីដ-១៩ ដូសជំរុញនេះ, គណៈកម្មការចំពោះកិច្ច ទទួលបន្ទុកលទ្ធកម្មវ៉ាក់សាំងកូវីដ-១៩ ត្រូវបន្តយកមិត្តចិនធ្វើជាបង្អែកផ្អែកយុទ្ធសាស្ត្រក្នុងការផ្គត់ផ្គង់វ៉ាក់សាំង ដល់ព្រះរាជាណាចក្រកម្ពុជា ហើយប្រភពផ្សេងទៀត នៅបន្តជាប្រភពគាំទ្រ ដែលបម្រើឱ្យតម្រូវការចាំបាច់នៃ ផែនការវ៉ាក់សាំងរបស់ព្រះរាជាណាចក្រកម្ពុជា ទាំងជាវ៉ាក់សាំងដូសជំរុញ ទាំងជាវ៉ាក់សាំងសម្រាប់ជុំទី២ ផ្អែកតាមលទ្ធភាពរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងការស្វែងរក និងទទួលបានវ៉ាក់សាំងកូវីដ-១៩។

- គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវរៀបចំយន្តការពិគ្រោះយោបល់ និងសម្របសម្រួលជាមួយយន្តការពាក់ព័ន្ធ និងរោងចក្រ-សហគ្រាស ម្ចាស់អាជីវកម្ម និងគ្រឹះស្ថានសុខាភិបាលឯកជន ដើម្បីឱ្យរោងចក្រ-សហគ្រាស និងម្ចាស់អាជីវកម្ម រួមចំណែកទទួលបន្ទុកក្នុងចំណាយលើវ៉ាក់សាំងកូវីដ-១៩ ជូនដល់កម្មករ និយោជិត និងបុគ្គលិករបស់ខ្លួន សំដៅបង្កើនល្បឿននៃការចាក់វ៉ាក់សាំងដូសជំរុញ និងជួយរំលែកបន្ទុកចំណាយរបស់រដ្ឋ។

- ក្រសួងសុខាភិបាល ត្រូវផ្តល់ការគាំទ្រនិងការសម្របសម្រួលតាមការចាំបាច់ ដើម្បីជួយឱ្យវិស័យឯកជនអាចនាំចូល និងផ្តល់សេវាចាក់វ៉ាក់សាំងដូសជំរុញនេះ ឱ្យបានទូលំទូលាយជូនដល់ប្រជាជន ប្រកបដោយសុវត្ថិភាព និងក្នុងថ្លៃសមរម្យ។

គ្រប់ក្រសួង-ស្ថាប័ន, គណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩, គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩, គណៈអភិបាលរាជធានី-ខេត្ត ព្រមទាំងយន្តការដែលមានការពាក់ព័ន្ធផ្សេងទៀត ត្រូវផ្សព្វផ្សាយ និងរៀបចំអនុវត្តគោលនយោបាយស្តីពីការចាក់វ៉ាក់សាំងដូសជំរុញនេះ ឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។ ទន្ទឹមនេះ រាជរដ្ឋាភិបាលសង្ឃឹមនិងជឿជាក់ថា ប្រជាពលរដ្ឋ និងវិស័យឯកជននឹងបន្តចូលរួមផ្តល់កិច្ចសហការជាមួយរាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយចាក់វ៉ាក់សាំងដូសជំរុញនេះ ឱ្យមានប្រសិទ្ធភាព ដើម្បីបង្កើតឱ្យមាន **"ភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយ"** ក្នុងការទប់ទល់នឹងមេរោគកូវីដ-១៩ ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការពារអាយុជីវិតប្រជាជន និងសម្រាប់ឈានឆ្ពោះទៅកាន់ផែនការនៃការបើកដំណើរការប្រទេសពេញលេញឡើងវិញលើគ្រប់វិស័យ និងការរស់នៅជាមួយនឹងវត្តមានជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី។

ថ្ងៃពុធ ៣រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ